# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្ដីខែសីហា



លេខ ២៩៨ ឆ្នាំទី២៥ ព.ស.២៥៦៩ គ.ស.២០២៥

Issue 298 Volume 25 BC 2569 BE 2025

# មាតិកា









**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម ឡាយ សំកុល

**អ្នកសម្របសម្រួលខ្លឹមសារ និងអភិវឌ្ឍ**

ឯកឧត្តម ខេង សិទ្ធិគុណ

ឯកឧត្តម ជាម សុផលមករា

ឯកឧត្តម ជួន ណា

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉េ

លោក សុង សុខភាក្ត័

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោក ធុន គីមជី

លោកស្រី សុខ សុជាតា


## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-២៩ )


- ប្រវត្តិសាស្ត្រកម្ពុជាកត់ត្រាទុកៈ គ្រប់កាលៈទេសៈ និងក្នុងស្ថានការណ៍ណាក៏ដោយក៏សម្ដេចតេជោ **ហ៊ុន សែន** មិនទៅណាចោលប្រជាពលរដ្ឋឡើយ ..... ១
- ថ្នាក់ដឹកនាំកម្ពុជា និងវៀតណាម បង្ហាញអំពីការពេញចិត្តចំពោះទំហំពាណិជ្ជកម្ម នៃប្រទេសទាំងពីរ និងគ្រោងសម្រេចឱ្យបាន ២០ពាន់លានដុល្លារអាមេរិក នៅពេលខាងមុខ ..... ៣
- ថ្ងៃឯករាជ្យជាតិវៀតណាមកាលពី៨០ឆ្នាំមុន មិនគ្រាន់តែសម្រាប់ប្រជាជនវៀតណាមប៉ុណ្ណោះទេប៉ុន្តែជាកម្លាំងជំរុញសម្រាប់ប្រជាជាតិក្នុងតំបន់រួមទាំងកម្ពុជាងើបឈរឡើងតស៊ូដើម្បីឯករាជ្យពីអាណានិគមនិយម ..... ៤
- ឯកឧត្តម **អ៊ុច បូរិទ្ធ** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ ..... ៦
- ព្រឹទ្ធសភាបោះឆ្នោតជ្រើសតាំងតំណាងព្រឹទ្ធសភាជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិទី៤ ..... ៧
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អញ្ជើញជាអធិបតីក្នុងពិធីប្រកាសលទ្ធផលនិងប្រគល់ពានរង្វាន់ដល់ម្ចាស់ជ័យលាភីផ្ទើមពានរង្វាន់ «ត្នោតមាស» ឆ្នាំ២០២៥ ..... ១០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលជាមួយមន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅក្នុងស្រុកចំការលើ ស្រុកស្ទឹងត្រង់ ស្រុកកំពង់សៀម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ..... ១២
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អញ្ជើញសួរសុខទុក្ខវីរយុទ្ធជនរងរបួសក្នុងពេលប្រយុទ្ធជាមួយកងទ័ពឈ្លានពានថៃ នៅតាមមន្ទីរពេទ្យជាតិ ចំនួន៤ ក្នុងរាជធានីភ្នំពេញ ..... ១៥
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អញ្ជើញសួរសុខទុក្ខ និងនាំយកអំណោយជូនកងពលតូចអន្តរាគមន៍លេខ៨ និងទីបញ្ជាការអន្តរាគមន៍ទួល៩៥ និងចុះសួរសុខទុក្ខវីរយុទ្ធជនកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប ..... ១៦
- ឯកឧត្តម **អ៊ុច បូរិទ្ធ**៖ ក្នុងកាលៈទេសៈដ៏លំបាកនេះ មានតែថ្នាក់ដឹកនាំប្រទេសជាតិរបស់យើងទើបយល់ច្បាស់អំពីទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋ ..... ១៧
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនវីរយុទ្ធជន និងជនភៀសសឹក នៅខេត្តឧត្តរមានជ័យ ..... ១៩
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុញ្ញាតឱ្យនិស្សិតទទួលបានអាហារូបករណ៍ទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្ដែងការគួរសម ..... ២១
- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា**៖ កម្ពុជាសូមស្វាគមន៍អ្នកសង្កេតការណ៍អន្តរជាតិ និងថែមកកាន់តំបន់ជម្លោះ ដើម្បីជាសាក្សីសម្លាភាព និងអនុញ្ញាតឱ្យពិភពលោកបានឃើញការពិត ..... ២៣
- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា**៖ អាជ្ញាធរគួរជំរុញប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនឱ្យមានការផលិតចំណីអាហារឱ្យបានច្រើន និងប្រកបដោយគុណភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ..... ២៤
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ..... ២៦


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ៣០-៧០ )


- គណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់វិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តព្រះសីហនុ ..... ៣០
- គណៈកម្មការទី២ព្រឹទ្ធសភា ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអាជ្ញាធរសេវាកម្មជាតិ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ..... ៣២
- គណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយមនុស្សធម៌ជូនប្រជាជនភៀសសឹក នៅក្រុងព្រះវិហារ ..... ៣៤
- គណៈកម្មការទី៦ព្រឹទ្ធសភា ពិភាក្សាការងារជាមួយនឹងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ..... ៣៦
- គណៈកម្មការទី៨ព្រឹទ្ធសភា សួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក និងពិនិត្យស្ថានភាពពលករធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃវិញ ..... ៣៨
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ សំណេះសំណាលជាមួយអាជ្ញាធរស្រុក ក្រុងទាំង១០ ក្នុងខេត្តកណ្ដាល ..... ៤០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញជួបសំណេះសំណាលគ្រួសាររីកងទ័ពពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តកំពង់ធំ ..... ៤២
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលជាមួយអាជ្ញាធរស្រុកដំណាក់ចង្អើរ និងក្រុងកែប ..... ៤៤
- ក្រុមសមាជិកព្រឹទ្ធសភា អញ្ជើញនាំយកថវិកាសង្គ្រោះសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋក្នុងស្រុកសណ្ដាន់ និងចុះសួរសុខទុក្ខគ្រួសាររីកងទ័ព ..... ៤៦
- ឯកឧត្តម **ម៉ម ប៊ុនណាង** ទទួលស្វាគមន៍សមាគមនិស្សិតកម្ពុជាប្រចាំប្រទេសចិនមកបំពេញទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភា ..... ៤៨
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា ..... ៥០
- ការទទួលពាក្យបណ្ដឹង ..... ៥២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨ ..... ៥៣
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ ..... ៦៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ..... ៧០


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៧១-៧៦ )


- ឯកឧត្តម **ឡាយ សំកុល** អរគុណថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក និងយុវជន ស.ស.យ.ក នៃអ.ពស ចំពោះការចូលរួមវិភាគទានថវិកា ស្បៀងអាហារដល់រីកងទ័ព និងប្រជាពលរដ្ឋភៀសសឹក ..... ៧១
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ..... ៧៣

# ប្រវត្តិសាស្ត្រកម្ពុជាកត់ត្រាទុកៈ គ្រប់កាលៈទេសៈ និងក្នុងស្ថានភាពណាក៏ដោយ ក៏សម្ដេចតេជោ ហ៊ុន សែន មិននៅណាចោលប្រជាពលរដ្ឋឡើយ

មិនថាប្រទេសជាតិស្ថិតក្នុងស្ថានភាពលំបាក ជួបឧបសគ្គ ចម្លាំងរាំងជល់ ឬក៏ស្ថិតក្នុងស្ថានការណ៍បែបណានោះទេ សម្ដេចអគ្គមហាសេនាធិបតីតេជោ **ហ៊ុន សែន** តែងតែនៅរួមរស់ជាមួយនឹងប្រជាពលរដ្ឋជាប់ជានិច្ច។ ជាក់ស្ដែង ដូចជា ការផ្ដួលរំលំរបបខ្មែរក្រហម ការស្ដារប្រទេសជាតិចេញពីគំនរផេះផង់នៃភ្លើងសង្គ្រាមដោយបាតដៃទទេ ការបង្រួបបង្រួម ឯកភាពទឹកដី ការអភិវឌ្ឍជាតិ កិត្យានុភាពជាតិក្នុងអន្តរជាតិ និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ជាដើម។

ហើយនាពេលថ្មីៗនេះ ក្នុងស្ថានភាពដែលប្រទេសជាតិជួបបញ្ហាប្រឈមជាថ្មីម្ដងទៀតជាមួយនឹងការឈ្លានពាន ពីប្រទេសថៃ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភា ប្រធានក្រុមឧត្ដមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ និងជាអគ្គកស្ដុភារជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធកម្ពុជា បាននិងកំពុងរួមសុខរួមទុក្ខជាមួយនឹង ប្រជាពលរដ្ឋ និងជាពិសេសជាមួយបងប្អូនវីរយុទ្ធជនយើង នៅគ្រប់លំដាប់ថ្នាក់ និងនៅតាមទីតាំងបញ្ជាការជួរមុខតាម បណ្ដោយព្រំដែនកម្ពុជា ព្រមទាំងបានរួមចំណែកជាមួយ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ដល់ប្រឹក្សាយោបល់/យុទ្ធសាស្ត្រ និងការលើកទឹកចិត្ត គាំទ្រគ្រប់បែបយ៉ាង គ្រប់ទិដ្ឋភាព ដោយគ្មានពេលសម្រាក ទាំងយប់ ទាំងថ្ងៃ ដើម្បីបុព្វហេតុ តែមួយគត់គឺការការពារឱ្យខាងតែបាននូវបូរណភាពទឹកដី និងដែនអធិបតេយ្យជាតិ ព្រមទាំងអាយុជីវិតប្រជាជាតិខ្មែរ ពីការឈ្លានពានរបស់ប្រទេសថៃ។ ឧត្ដមគតិនិងសកម្មភាព ស្នេហាជាតិរបស់**សម្ដេចតេជោ** ជាគំរូនិងជាកិត្តិយស ដ៏ឧត្ដុង្គឧត្ដមបំផុតសម្រាប់ប្រជាជាតិខ្មែរទាំងមូល។



*សម្ដេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

ប្រជាជនកម្ពុជាមានមោទនភាពបំផុតនិងសូមសម្ដែងនូវគារវកិច្ច ប្រកបដោយកតញ្ញូតាធម៌និងកតវេទិតាធម៌យ៉ាង ស្មោះស្ម័គ្របំផុតគោរពជូន **សម្ដេចអគ្គមហាសេនាបតីតេជោ** ដែលជាស្ថាបនិក មគ្គុទ្ទេសក៍ឯក និងប្រតិបត្តិករ នយោបាយ ឈ្នះ-ឈ្នះ និងដែលបានតស៊ូលះបង់អស់កម្លាំងកាយ-ចិត្តនិងស្មារតី និងជម្នះរាល់ឧបសគ្គស្ទើរពេញមួយ ជីវិតរបស់**សម្ដេច** ដើម្បីបុព្វហេតុនៃការរំដោះអាយុជីវិតប្រជាជនកម្ពុជាគ្រប់ៗរូបឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ពីការឈ្លានពានរបស់ថៃ ក្នុងបុព្វហេតុសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គមជាតិមាតុភូមិ។

ទន្ទឹមនឹងនេះ ប្រជាជនកម្ពុជាសូមវាយតម្លៃខ្ពស់ និងសម្ដែងនូវគារវកិច្ចគោរពចំពោះវីរភាពដ៏អង់អាចក្លាហានមោះមុត



*សកម្មភាពដ៏អង់អាចរបស់សម្ដេចតេជោ ហ៊ុន សែន រួមចំណែកផ្ដល់យោបល់/យុទ្ធសាស្ត្រតាមប្រព័ន្ធវីដេអូជាមួយសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី, ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ, អគ្គមេបញ្ជាការកងទ័ព, និងបញ្ជាការកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់*

របស់វីរយុទ្ធជនដែលបាននិងកំពុងលះបង់កម្លាំងកាយចិត្ត បូជាអាយុជីវិត តស៊ូ អត់ធ្មត់ ក្រាញនឿល ក្នុងការការពារជាតិមាតុភូមិកម្ពុជា និងសូមសម្តែងនូវមោទនភាពជាតិខ្ពស់ចំពោះស្មារតីស្នេហាជាតិរបស់បងប្អូនជនរួមជាតិទាំងអស់ទាំងក្នុង និងក្រៅប្រទេស ដែលបានសម្តែងឱ្យឃើញនូវកម្លាំងមហាសាមគ្គីឯកភាពជាតិជាធ្លុងមួយ ដើម្បីបុព្វហេតុជាតិមាតុភូមិវាយបំបាក់អំពើឈ្លានពានរបស់កងទ័ពថៃ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងវៃឆ្លាតរបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចធិបតី **ហ៊ុន ម៉ាណែត** ប្រមុខរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

ព្រមជាមួយគ្នានេះ ប្រជាជនកម្ពុជាក៏សូមអរគុណឯកឧត្តម **ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាម៉េរិក ដែលបានអន្តរាគមន៍ឱ្យបញ្ចប់សង្គ្រាមនេះ ជាបន្ទាន់ ហើយក៏សូមអរគុណឯកឧត្តម Anwar Ibrahim នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាប្រធានប្តូរវេនអាស៊ាន ព្រមទាំងសាធារណរដ្ឋប្រជាមានិតចិន ដែលបានសម្របសម្រួល រៀបចំឱ្យមានកិច្ចចរចារវាងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនាយករដ្ឋមន្ត្រីស្តីទីថៃ ដែលនាំឱ្យមានបទឈប់បាញ់ នៅវេលាម៉ោង១២:០០នាទីយប់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ «កម្ពុជាជាប្រទេសដែលស្រឡាញ់សន្តិភាព ចង់រស់នៅប្រកបដោយសន្តិសហវិជ្ជមានជាមួយបណ្តាប្រទេសទាំងអស់នៅក្នុងពិភពលោក។ ប៉ុន្តែ ការស្រឡាញ់សន្តិភាពរបស់កម្ពុជា មិនមានន័យថាជាការបោះបង់សិទ្ធិអធិបតេយ្យក្នុងការការពារបូរណភាពដែនដីរបស់ខ្លួននោះទេ»។



សម្តេចតេជោ ហ៊ុន សែន អញ្ជើញពិនិត្យផែនទីភូមិសាស្ត្រ

គួររំលឹកផងដែរថា ផ្តើមចេញពីមហិច្ឆតាដ៏អាក្រក់ជ្លជាតិ កងទ័ពថៃបានធ្វើសកម្មភាពឈ្លានពានយ៉ាងកំរោលគឃ្លើន សាហាវព្រៃផ្សៃ អមនុស្សធម៌ ប្រើគ្រប់កលល្បិចនិងបានធ្វើឱ្យសភាពការណ៍នៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ មានការវិវត្តយ៉ាងតានតឹង និងប្រកបដោយគ្រោះថ្នាក់បំផុត រហូតដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ទាហានថៃបានជ្រៀតចូលក្នុងទឹកដីកម្ពុជាដោយខុសច្បាប់ ហើយបាញ់សម្លាប់យោធាកម្ពុជាម្នាក់ នៅតំបន់មុំបី និងបានបិទច្រកព្រំដែនដោយឯកតោភាគី និងការគំរាមកាត់ផ្តាច់សេវាអ៊ីនធឺណិត អគ្គិសនី និងឈប់ផ្គត់ផ្គង់ប្រេងឥន្ធនៈមកកម្ពុជាសំដៅខ្ទប់សេដ្ឋកិច្ចកម្ពុជា ព្រមទាំងធ្វើការប្រមាថយ៉ាងធ្ងន់ធ្ងរមកលើកម្ពុជា។ នៅព្រលឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ កងទ័ពថៃ បានចូលវាយលួសបន្លាតាមជើងប្រាសាទតាមាន់ធំ និងបានបើកការបាញ់ប្រហារមុន មកលើកងទ័ពកម្ពុជា នៅតំបន់ប្រាសាទតាមាន់ធំ តមកទៀតបានវាយប្រហារនៅប្រាសាទតាក្របី តំបន់ភ្នំខ្មោច តំបន់មុំបី និងនៅតំបន់ជាច្រើនទៀត តាមខ្សែបន្ទាត់ព្រំដែន រហូតដល់វេលាម៉ោង១២:០០នាទីយប់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ទើបបញ្ឈប់ការវាយប្រហារមកលើកម្ពុជា តាមរយៈបទឈប់បាញ់៕

អត្ថបទ៖ នាយកដ្ឋានព័ត៌មាន, រូបភាព៖ Telegram Channel សម្តេចតេជោ



សម្តេចតេជោ ហ៊ុន សែន រួមចំណែកផ្តល់យោបល់/យុទ្ធសាស្ត្រតាមប្រព័ន្ធវីដេអូ

# ថ្នាក់ដឹកនាំកម្ពុជា និងវៀតណាម បង្ហាញអំពីការពេញចិត្តចំពោះទំហំពាណិជ្ជកម្ម នៃប្រទេសទាំងពីរ និងគ្រោងសម្រេចឱ្យបាន២០ពាន់លានដុល្លារអាម៉េរិក នៅពេលខាងមុខ





*សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម តូ ឡឹម*

ក្នុងឱកាសដែលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម តាមប្រព័ន្ធវីដេអូ នារសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានសម្តែងនូវការពេញចិត្តចំពោះទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ រយៈពេល៧ខែដើមឆ្នាំ២០២៥ មានប្រមាណ៧ពាន់លានដុល្លារអាម៉េរិក ក្នុងនោះកម្ពុជាបាននាំចេញទំនិញទៅកាន់ប្រទេសវៀតណាមប្រមាណ៣,៨ពាន់លានដុល្លារអាម៉េរិក ហើយវៀតណាមបាននាំចូលមកកម្ពុជាមានចំនួន៣,២ពាន់លានដុល្លារអាម៉េរិក។ កម្ពុជានិងវៀតណាម គ្រោងសម្រេចឱ្យបាននូវផែនការទំហំពាណិជ្ជកម្មជាមួយគ្នា ២០ពាន់លានដុល្លារអាម៉េរិកនៅពេលខាងមុខ។

**សម្តេចតេជោ** បានបញ្ជាក់ថា វៀតណាមគឺជាទីផ្សារនាំទំនិញរបស់កម្ពុជាដ៏ធំលំដាប់ទី៣ ដូច្នេះជាសក្តានុពលមួយ នៃការធ្វើពាណិជ្ជកម្មជាមួយគ្នា ដែលឆ្លុះបញ្ចាំងអំពីទំនាក់ទំនងដ៏ល្អរវាងកម្ពុជានិងវៀតណាម ក្នុងឋានៈជាប្រទេសភូមិផងរបងជាមួយគ្នា ហើយមានព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការជាមួយគ្នាដែលបម្រើផលប្រយោជន៍ទៅវិញទៅមក។

**សម្តេចតេជោ** បានលើកឡើងអំពីចំណុចសំខាន់ៗ ដែលពាក់ព័ន្ធនឹងទំនាក់ទំនងនិងសហប្រតិបត្តិការដ៏ល្អប្រពៃរវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិនៃប្រទេសទាំងពីរ ដែលត្រូវបានពង្រឹងជាមួយគ្នាតាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់កំពូល។

នៅក្នុងឱកាសនោះ ឯកឧត្តម **តូ ឡឹម** បានសម្តែងនូវសេចក្តីពេញចិត្តយ៉ាងខ្លាំងចំពោះទំនាក់ទំនងកម្ពុជានិងវៀតណាម តាំងពីអតីតកាលរហូតដល់ពេលបច្ចុប្បន្ន ដែលពូនជ្រំបន្តពីសម្តេចតេជោ **ហ៊ុន សែន** នាពេលកន្លងទៅ និងបន្តមកដល់ក្រោមការដឹកនាំរបស់សម្តេចមហបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរមានភាពល្អប្រសើរជាលំដាប់។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានជម្រាបប្រាប់ឯកឧត្តម **តូ ឡឹម** ថា នៅពេលខាងមុខ ពេលគឺនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៥ **សម្តេច**នឹងអញ្ជើញទៅចូលរួមក្នុងពិធីបុណ្យខួប៨០ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិរបស់វៀតណាម។ ឯកឧត្តម **តូ ឡឹម** បានសម្តែងនូវការអរគុណចំពោះ**សម្តេចតេជោ** ដែលបានបញ្ជាក់យ៉ាងច្បាស់ អំពីវត្តមានរបស់**សម្តេច**ក្នុងខួប៨០ឆ្នាំនៃបុណ្យឯករាជ្យជាតិវៀតណាម។ ឯកឧត្តមក៏បានចាត់ទុកវត្តមានរបស់**សម្តេចតេជោ** ថាជាការឆ្លុះបញ្ចាំងអំពីទំនាក់ទំនងដ៏រឹងមាំរវាងកម្ពុជានិងវៀតណាម ហើយឯកឧត្តមបានប្តេជ្ញាធ្វើយ៉ាងណាពូនជ្រំទំនាក់ទំនង ឱ្យកាន់តែរឹងមាំបន្ថែមទៀតឱ្យសមជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី សហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង៕

អត្ថបទ៖ នាយកដ្ឋានព័ត៌មាន

រូបភាព៖ Telegram Channel សម្តេចតេជោ

# ថ្ងៃឯករាជ្យជាតិវៀតណាមកាលពី៨០ឆ្នាំមុន មិនគ្រាន់តែសម្រាប់ប្រជាជនវៀតណាមប៉ុណ្ណោះទេប៉ុន្តែជាកម្លាំងជំរុញសម្រាប់ប្រជាជាតិក្នុងតំបន់រួមទាំងកម្ពុជាងើបឈរឡើងតស៊ូដើម្បីឯករាជ្យពីអាណានិគមនិយម

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា ថ្ងៃឯករាជ្យជាតិរបស់វៀតណាម កាលពី៨០ឆ្នាំមុន មិនគ្រាន់តែសម្រាប់ប្រជាជនវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែគឺជាកម្លាំងជំរុញសម្រាប់បណ្តាប្រជាជាតិក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមទាំងកម្ពុជាផងដែរ ងើបឈរឡើងតស៊ូដើម្បីឯករាជ្យពីអាណានិគមនិយម។



*សម្តេចតេជោអញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៨០ឆ្នាំ នៃទិវាឯករាជ្យរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម នៅរាជធានីភ្នំពេញ*

**សម្តេចតេជោ** បានលើកឡើងដូច្នេះនៅពេលដែល **សម្តេច**អញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៨០ឆ្នាំ នៃទិវាឯករាជ្យរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (២ កញ្ញា ១៩៤៥ - ២ កញ្ញា ២០២៥) ដែលរៀបចំដោយស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភូគីត្រា រាជធានីភ្នំពេញ នាល្ងាចថ្ងៃព្រហស្បតិ៍ ទី២១ ខែសីហា ឆ្នាំ២០២៥។

**សម្តេចតេជោ** បានមានប្រសាសន៍ថា ទិវាឯករាជ្យ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៥ ដែលនឹងមកដល់នាពេលខាងមុខនេះ ប្រជាជនវៀតណាមនឹងចូលរួមអបអរសាទរ ដើម្បីរំឭកព្រឹត្តិការណ៍ដ៏សំខាន់នេះ និងចងចាំអំពីវីរភាពក្លាហានរបស់យុទ្ធជន ដែលបានតស៊ូប្រយុទ្ធដើម្បីបុព្វហេតុជាតិ។ ទឹកចិត្តស្នេហាជាតិ និងពលិកម្មរបស់ពួកគាត់ដើម្បីទទួលបានសិទ្ធិស្វ័យសម្រេច ត្រូវបានចងចាំនិងដឹងគុណជានិច្ច។

**សម្តេចតេជោ** ក៏បានសម្តែងការអបអរសាទរចំពោះមិត្តវៀតណាម ដែលបានធ្វើដំណើរយ៉ាងស្វាហាប់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជាពិសេសការទទួលបានកំណើនសេដ្ឋកិច្ចជាង៧ភាគរយ ក្នុងឆ្នាំ២០២៤។ **សម្តេចតេជោ** បានបង្ហាញជំនឿជឿជាក់ថា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់បក្សកុម្មុយនីស្តវៀតណាម ដែលមានឯកឧត្តម **តូ ឡឹម** ជាអគ្គលេខាធិការបក្ស ប្រជាជនវៀតណាម នឹងសម្រេចបានទិសដៅសហស្សវត្សរ៍ចំនួនពីរ៖

១-ជាប្រទេសកំពុងអភិវឌ្ឍ ដែលមានឧស្សាហកម្មទំនើប និងមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក្នុងឱកាសខួប ១០០ឆ្នាំ នៃការបង្កើត



*សម្តេចតេជោ អញ្ជើញមានប្រសាសន៍*





*ទិដ្ឋភាពក្នុងពិធីអបអរសាទរខួបលើកទី៨០ឆ្នាំ នៃទិវាឯករាជ្យរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម នៅរាជធានីភ្នំពេញ*

បក្សកុម្មុយនីស្តវៀតណាម។

២-ជាប្រទេសសង្គមនិយម ដែលមានការអភិវឌ្ឍនិងមានប្រាក់ចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៤៥ ស្របពេលខួបលើកទី១០០ នៃការបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ក៏ដូចជាការលើកស្ទួយកិត្យានុភាព និងតួនាទីរបស់វៀតណាមនៅលើឆាកតំបន់ និងអន្តរជាតិ។

ក្នុងពិធីអបអរសាទរនាពេលនោះ ឯកឧត្តម Nguyen Minh Vu ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំកម្ពុជា បានចាត់ទុកការអញ្ជើញចូលរួមជាកិត្តិយសរបស់សម្តេចតេជោ **ហ៊ុន សែន** និងថ្នាក់ដឹកនាំកម្ពុជាដទៃទៀត ជាសក្ខីភាពដ៏រឹងមាំនៃចំណងសាមគ្គីភាព មិត្តភាពជាប្រពៃណី និងក្តីស្រលាញ់ដ៏ជ្រាលជ្រៅចំពោះប្រជាជនវៀតណាម។

សូមជម្រាបថា ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ ជាថ្ងៃដ៏មហោឡារិកនៃការទទួលបានឯករាជ្យរបស់ប្រជាជាតិវៀតណាម ហើយក៏ជាថ្ងៃបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលសព្វថ្ងៃ គឺសាធារណរដ្ឋសង្គមនិយមវៀតណាម។ ថ្នាក់ដឹកនាំនិងប្រជាជនវៀតណាម តែងបានប្រារព្ធពិធីអបអរសាទរថ្ងៃឯករាជ្យរបស់ខ្លួនយ៉ាងអធិកអធមជារៀងរាល់ឆ្នាំ៕

ប្រភព៖ ទំព័រហ្វេសប៊ុកសម្តេចតេជោ

សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន





*សម្តេចតេជោ អញ្ជើញទស្សនាពិព័រណ៍សមិទ្ធផលនានា*

# ឯកឧត្តម អ៊ុច បូររិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤

របៀបវារៈចំនួន៤ ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ លើកយកមកប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃចន្ទ ទី៤ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោង ៨:៣០នាទី នៅវិមានព្រឹទ្ធសភា។

របៀបវារៈចំនួន៤នោះ រួមមាន៖

**១-ពិនិត្យនិងសម្រេចលើសុពលភាពបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ១រូប តំណាងព្រឹទ្ធសភា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**២-ពិនិត្យសំណើរបស់សមាជិកព្រឹទ្ធសភាស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ។**

**៣-កំណត់កាលបរិច្ឆេទនិងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៤-ផ្សេងៗ។**



*ឯកឧត្តម អ៊ុច បូររិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

ឆ្លងតាមការពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃចន្ទ ទី៤ ខែសីហា ឆ្នាំ២០២៥ នាវេលាម៉ោង៩:៣០នាទីព្រឹក នៅវិមានព្រឹទ្ធសភា ដើម្បីបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ សម្រាប់ធ្វើការបោះឆ្នោតជ្រើសតាំងតំណាងព្រឹទ្ធសភា ជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិទី៤ (២០២៥-២០៣០) ១រូប៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបោះឆ្នោតជ្រើសតាំងតំណាងព្រឹទ្ធសភា ជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិទី៤






*ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១, ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា ក្រោកឈរស្មឹងស្មាធិ៍ ដើម្បីគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ*

នាព្រឹកថ្ងៃចន្ទ ទី៤ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោង៩:៣០នាទី ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៥រូប។

មុននឹងចាប់ផ្តើមដំណើរការអង្គប្រជុំ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានស្នើដល់សមាជិក សមាជិកាព្រឹទ្ធសភា និងអ្នកចូលរួមក្នុងអង្គប្រជុំក្រោកឈរស្មឹងស្មាធិ៍ ដើម្បីគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈតែមួយគឺ ការបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ១រូប តំណាងព្រឹទ្ធសភា។




ដោយអនុលោមតាមមាត្រា៦ និងមាត្រា៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានស្នើសុំឱ្យព្រឹទ្ធសភាជ្រើសតាំងឥស្សរជន១រូប ជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអាណត្តិទី៤ (២០២៥-២០៣០) តំណាងព្រឹទ្ធសភាជំនួស ឯកឧត្តម **លី ណារុន** ដែលត្រូវបញ្ចប់អាណត្តិ។

ស្របតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៥ និងការផ្សព្វផ្សាយជាសាធារណៈ តាមសេចក្តីជូនដំណឹងលេខ ៨៧២/០៧២៥/អ.ពស/នវ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋាន




*ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ*

ព្រឹទ្ធសភា បានទទួលពាក្យសុំ និងធ្វើការពិនិត្យលើឯកសារពាក់ព័ន្ធ ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម្រេចលើសុពលភាពបេក្ខជនរួចមក សម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ បានដំណើរការនីតិវិធីបោះឆ្នោត ដោយជ្រើសរើសឯកឧត្តម **ឡាយ សំកុល** ជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ សម្រាប់អាណត្តិទី៤ (២០២៥-២០៣០) តំណាងព្រឹទ្ធសភាដោយទទួលបានការគាំទ្រចំនួន៥៤សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានោះ ក្នុងនាមជាបេក្ខជនជាប់ឆ្នោត ឯកឧត្តម **ឡាយ សំកុល** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតគោរពជូន **សម្តេចតេជោប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់សេចក្តីទុកចិត្តនិងគោរពនិងថ្វាយជូន **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា** ព្រមទាំងសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម ដែលបានបោះឆ្នោតគាំទ្រដល់ ឯកឧត្តម **ឡាយ សំកុល** ធ្វើជាតំណាងព្រឹទ្ធសភានៅក្នុងក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងបានប្តេជ្ញាចិត្តខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា និងស្មារតី ដើម្បីបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមនេះឱ្យទទួលបានជោគជ័យ និងប្រកបដោយការទទួលខុសត្រូវខ្ពស់។



*ឯកឧត្តម ឡាយ សំកុល ឡើងប្តេជ្ញាចិត្ត*

ក្នុងឱកាសនោះផងដែរ ឯកឧត្តម **ឡាយ សំកុល** បានសម្តែងគារវកិច្ចប្រកបដោយកតញ្ញូតាធម៌និងកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុតគោរពជូន **សម្តេចតេជោប្រធានព្រឹទ្ធសភា** ដែលជាស្ថាបនិក មគ្គុទ្ទេសក៍ឯក និងប្រតិបត្តិករនយោបាយឈ្នះ-ឈ្នះ ដែលបានតស៊ូលះបង់កម្លាំងកាយចិត្តនិងស្មារតី និងជម្នះរាល់ឧបសគ្គស្ទើរពេញមួយជីវិតរបស់**សម្តេច** ដើម្បី

បុព្វហេតុនៃការរំដោះអាយុជីវិតប្រជាជនកម្ពុជាគ្រប់ៗរូបឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ សុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គមជាតិមាតុភូមិ។ ថ្មីៗនេះ នៅចំពោះមុខសភាពការណ៍ដែលប្រទេសជាតិនិងប្រជាជនកម្ពុជា កំពុងរងគ្រោះពីការវាយប្រហារឈ្លានពានរបស់កងទ័ពថៃ **សម្តេចតេជោ**ពិតជាបានបង្ហាញយ៉ាងច្បាស់នូវភាពអង់អាចនិងការលះបង់ដ៏ធំធេងបំផុតរបស់**សម្តេច** ក្នុងនាមជាប្រធានព្រឹទ្ធសភា ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាអគ្គភស្តុភារជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធ **សម្តេចតេជោ**បានរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋ និងជាពិសេសបាននិងកំពុងរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជានិងបងប្អូនវីរយុទ្ធជនយើងនៅគ្រប់លំដាប់ថ្នាក់ នៃគ្រប់ទីតាំងបញ្ជាការជួរមុខតាមបណ្តោយព្រំដែនកម្ពុជា ក្នុងការផ្តល់ប្រឹក្សាយោបល់/យុទ្ធសាស្ត្រ និងការលើកទឹកចិត្តគាំទ្រគ្រប់បែបយ៉ាងនិងគ្រប់ទិដ្ឋភាពដោយគ្មានពេលសម្រាក មិនថាពេលយប់ ឬថ្ងៃ និងមិនហ៊ានសូម្បីតែឈឺ ដើម្បីបុព្វហេតុតែមួយគត់គឺការការពារបូរណភាពទឹកដី និងដែនអធិបតេយ្យជាតិ ព្រមទាំងអាយុជីវិតរបស់ប្រជាជាតិខ្មែរពីការឈ្លានពាន។ គំរូវីរភាពរបស់**សម្តេចតេជោ** ត្រូវបានចារទុកក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលយើងខ្ញុំទាំងអស់គ្នាក៏ដូចប្រជាជនកម្ពុជាគ្រប់រូបសូមគោរពដឹងគុណបំផុត និងគាំទ្រយ៉ាងពេញទំហឹង។

ឆ្លៀតឱកាសមង្គលសួស្តីប្រពៃថ្លៃថ្លានៃពិធីចម្រើនជន្មាយុរបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា** នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** ក្នុងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានសម្តែងនូវអំណរសាទរប្រកបដោយក្តីសោមនស្សរីករាយបំផុតគោរពជូន **សម្តេចតេជោ**និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមមេត្តាតាមជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល គ្រប់ប្រការជូន**សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងសម័យប្រជុំព្រឹទ្ធសភាជាសាមញ្ញ នីតិកាលទី៥*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីប្រកាសលទ្ធផល និងប្រគល់ពានរង្វាន់ដល់ម្ចាស់ជ័យលាភីផ្ទើមពានរង្វាន់ «ត្នោតមាស» ឆ្នាំ២០២៥



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងកម្មវិធីប្រកាសលទ្ធផល និងប្រគល់ពានរង្វាន់ដល់ម្ចាស់ជ័យលាភីផ្ទើម*

នារសៀលថ្ងៃសៅរ៍ ទី២៦ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសលទ្ធផល និងប្រគល់ពានរង្វាន់ដល់ម្ចាស់ជ័យលាភីផ្ទើមពានរង្វាន់ «ត្នោតមាស» ឆ្នាំ២០២៥ នៅស្នាក់ការមូលនិធិគីណាល់ ស្ថិតក្នុងសង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញមានប្រសាសន៍*

ថ្លែងទៅកាន់អង្គពិធីដែលមានអ្នកចូលរួមប្រមាណជាង៥០០នាក់ **ឯកឧត្តមអនុប្រធានទី១** បានពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខនិងក្ដីនឹករលឹកពីសំណាក់ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង**សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និង**លោកជំទាវបណ្ឌិត** និងបានថ្លែងអំណរគុណចំពោះលោកឧកញ៉ាឱសថបណ្ឌិត **ហៃ លីអ៊ាង** ប្រធានមូលនិធិគីណាល់ និងក្រុមហ៊ុនខនហ្វីរេល ព្រមទាំងលោកជំទាវ ដែលបានរៀបចំពិធីប្រកួតប្រជែងភាពច្នៃប្រឌិតផលិតផលកសិកម្មកម្ពុជាដណ្ដើមពានរង្វាន់ «ត្នោតមាស» ដែលជាការរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍធនធានមនុស្ស ស្របតាមអាទិភាពទាំង៥ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

**ឯកឧត្តមអនុប្រធានទី១** បានបន្ថែមថា ទិសដៅមូលនិធិគីណាល់ បានបង្ហាញឱ្យឃើញពីការអនុវត្តនយោបាយចែករំលែក ដែលជាអនុសាសន៍ដ៏ថ្លៃថ្លាឧត្តុង្គឧត្តមរបស់ **សម្ដេចតេជោប្រធានព្រឹទ្ធសភា** សំដៅលើកកម្ពស់សុខុមាលភាពនិងជីវភាពប្រជាជន ពូនជ្រំថ្នាលបន្តវេនដ៏ល្អប្រសើរដល់សិស្សានុសិស្ស យុវជនជា «ទំពាំងស្នងឫស្សី» សម្រាប់អនាគតប្រទេសជាតិ។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអនុប្រធានទី១** បានថ្លែងជម្រាបអង្គពិធីពីមូលហេតុនៃសកម្មភាពឈ្លានពាន




*ទិដ្ឋភាពក្នុងពិធីប្រកាសលទ្ធផលនិងប្រគល់ពានរង្វាន់ដល់ម្ចាស់ជ័យលាភីផ្ទើម*

ដែលបានគ្រោងទុកជាមុនរបស់ថៃ ដែលតែងតែចិញ្ចឹមមហិច្ឆតាស្រេកឃ្លានចង់បានទឹកដីកម្ពុជា និងបានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរ យុវជន យុវនារី សិស្ស និស្សិតទាំងអស់ បើទោះជាមានជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ និន្នាការនយោបាយផ្សេងគ្នាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវតែរួបរួមសាមគ្គីឯកភាពជាតិជាធ្លុងមួយ ពួតដៃជាមួយរាជរដ្ឋាភិបាល និងវីរកងទ័ពខ្មែរ នៅក្នុងការប្តូរផ្តាច់ការពារដែនអធិបតេយ្យរបស់កម្ពុជា ប្រឆាំងនិងវាយបំបាក់អំពើឈ្លានពានដ៏គឃ្លើនរបស់កងកម្លាំងប្រដាប់អាវុធថៃ។ ឯកឧត្តម បានសង្កត់ធ្ងន់ថា «យើងទាំងអស់គ្នាមានឈាមជ័រខ្មែរតែមួយ យើងកើតមកជាខ្មែរនៅលើទឹកដីនេះ គឺមាតុភូមិរបស់យើងទាំងអស់គ្នា។ ដូចនេះ កាតព្វកិច្ចរបស់យើង គឺពួតដៃសាមគ្គីការពារទឹកដីមាតុភូមិនេះ មិនឱ្យបាត់បង់សូម្បីតែមួយមិល្លីម៉ែត្រក៏ដោយ»។

ជាទីបញ្ចប់ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងការអបអរសាទរចំពោះក្រុមនិស្សិតដែលទទួលបានជ័យលាភីទាំង៣ក្រុម ដោយចំណាត់ថ្នាក់លេខ១និងលេខ២ បានទៅលើក្រុមនិស្សិតមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងចំណាត់ថ្នាក់លេខ៣ បានទៅលើក្រុមនិស្សិតមកពីវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ព្រមទាំងបានលើកទឹកចិត្តដល់ក្រុមនិស្សិតដែលមិនទទួលបានជោគជ័យនៅឆ្នាំនេះ ឱ្យបន្តខិតខំប្រឹងប្រែងទៀត។ ឯកឧត្តម ក៏បានធ្វើជាអធិបតីក្នុងការប្រគល់ពានរង្វាន់ និងលិខិតសរសើរជូនដល់ក្រុមនិស្សិតដែលទទួលបានជ័យលាភីលេខ១ ផងដែរ។

គួរបញ្ជាក់ថា ពានរង្វាន់ «ត្នោតមាស» ដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០១៨ មានការទទួលស្គាល់និងល្បីល្បាញគួរឱ្យកត់សម្គាល់តាមរយៈការចុះឈ្មោះចូលរួមប្រកួតប្រជែងជារៀងរាល់ឆ្នាំ។ កាលពីឆ្នាំ២០១៨ ដែលជាឆ្នាំដំបូង មាននិស្សិតតែ១៩ក្រុមប៉ុណ្ណោះបានចុះឈ្មោះចូលរួមប្រកួត។ ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំ ពិធីប្រកួតនេះទទួលបានការគាំទ្រកាន់តែច្រើន ដោយឆ្នាំ២០២៥ មាននិស្សិតចំនួន ៦០ក្រុម មកពី១១គ្រឹះស្ថានឧត្តមសិក្សានៅទូទាំងប្រទេសកម្ពុជា បានចុះឈ្មោះចូលរួមប្រកួតប្រជែងក្រោមប្រធានបទស្តីពី «ការកែច្នៃផលិតផលស្វាយ ព្រមទាំងសិក្សាលក្ខណៈបច្ចេកទេសលើខ្សែច្រវាក់ផលិតកម្មប្រកបដោយនវានុវត្តន៍សម្រាប់ទីផ្សារ» ដែលឆ្លុះបញ្ចាំងពីសក្តានុពលដ៏សំខាន់របស់ប្រទេសកម្ពុជា ក្នុងការផលិតនិងនាំចេញផលិតផលស្វាយ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូរិទ្ធ ថតរូបអនុស្សាវរីយ៍ជាមួយបេក្ខជនជាប់ជ័យលាភី*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាល ជាមួយមន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅក្នុងស្រុកចំការលើ ស្រុកស្ទឹងត្រង់ ស្រុកកំពង់សៀម ក្រុងកំពង់ចាម ខេត្តកំពង់ចាម





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលជាមួយមន្ត្រីរាជការ ប្រជាពលរដ្ឋ នៅស្រុកចំការលើ*

ចាប់ផ្តើមពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ) ដឹកនាំដោយ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងប្រជាពលរដ្ឋក្នុងស្រុកចំការលើចំនួន៣២០នាក់ ស្រុកស្ទឹងត្រង់ចំនួន៦២០នាក់, ស្រុកកំពង់សៀមនិងក្រុងកំពង់ចាម ខេត្តកំពង់ចាមចំនួន៩៨០នាក់ សរុបទាំង៣ស្រុក មានចំនួន១.៩២០នាក់។



នៅក្នុងគ្រប់ពិធីសំណេះសំណាល **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានពាំនាំប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការជួបជុំដែលមានវិសាលភាពទូលំទូលាយជាងសព្វមួយដង ទោះបីនៅក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងប្រឈមមុខនឹងការឈ្លានពានយ៉ាងគឃ្លើនព្រៃផ្សៃរបស់ប្រទេសថៃ មកលើបូរណភាពដែនដី នៃព្រះរាជាណាចក្រកម្ពុជា។



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញចុះជួបសំណេះសំណាលជាមួយមន្ត្រីរាជការ ប្រជាពលរដ្ឋ ក្នុងស្រុកស្ទឹងត្រង់*

**ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានជម្រាបជូនអង្គពិធីអំពីសុច្ឆន្ទៈរបស់កម្ពុជា ក្រោមអនុសាសន៍ដ៏ឧត្តុង្គឧត្តម




*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញសំណេះសំណាលជាមួយមន្ត្រីរាជការ ប្រជាពលរដ្ឋ ក្នុងស្រុកកំពង់សៀម និងក្រុងកំពង់ចាម*

ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ**និងក្រោមការដឹកនាំប្រកបដោយថាមពលនិងវៃឆ្លាតរបស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាក្នុងការចាត់វិធានការរក្សាការពារបូរណភាពដែនដីកម្ពុជា និងដោះស្រាយវិវាទព្រំប្រទល់ជាមួយប្រទេសថៃដោយសន្តិវិធីដោយផ្អែកលើច្បាប់ លើធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ានដើម្បីនិរន្តរភាពសន្តិភាពសម្រាប់ប្រជាជនទាំងពីរ(កម្ពុជា និងថៃ)។ ឯកឧត្តមបានសង្កត់ធ្ងន់ថា «ការស្រឡាញ់សន្តិភាពរបស់កម្ពុជា មិនមានន័យថា កម្ពុជាបោះបង់សិទ្ធិអធិបតេយ្យក្នុងការការពារបូរណភាពដែនដីរបស់ខ្លួននោះទេ»។

ទន្ទឹមនឹងនោះ អង្គពិធីបានសម្តែងក្តីអំណរសាទរនិងវាយតម្លៃខ្ពស់បំផុតចំពោះភាពចាស់ទុំនយោបាយ ភាពទន់ភ្លន់ម៉ឺងម៉ាត់របស់**សម្តេចធិបតី** ក្នុងនាមជាអ្នកដឹកនាំរដ្ឋ នៅក្នុងការចរចាបញ្ឈប់ការវាយប្រហារគ្នាជាមួយភាគីថៃ នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី២៨ ខែកក្កដា កន្លងទៅ។ ជាមួយគ្នានោះ **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានធ្វើការកត់សម្គាល់ប្រកបដោយមោទនភាពជាតិខ្ពស់និងក្តីរំភើបជាអតិបរិមា ចំពោះស្មារតីស្នេហាជាតិមាតុភូមិ និងសាមគ្គីឯកភាពជាតិជាធ្លុងមួយរបស់បងប្អូនប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅទូទាំងប្រទេស ក្នុងការចូលរួមឧបត្ថម្ភគាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈ ជួយដល់វីរយុទ្ធជនដែលកំពុងក្រាញននៀលនៅសមរភូមិ តស៊ូ បូជាសាច់ស្រស់ឈាមស្រស់ ដើម្បីការពារទឹកដីមាតុភូមិកម្ពុជា។

ឆ្លៀតនៅក្នុងឱកាសនោះ ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានគូសបញ្ជាក់ថា ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ គឺជាការអនុវត្តសមស្របតាមច្បាប់អន្តរជាតិ ជាពិសេសមាត្រា៨ នៃអនុសញ្ញាអង្គការសហប្រជាជាតិ ឆ្នាំ១៩៦១ និងតាមប្រវត្តិសាស្ត្រកម្ពុជាដែលធ្លាប់មានក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ និងច្បាប់ដកហូតសញ្ជាតិឆ្នាំ១៩៦៨។ម្យ៉ាងទៀត ការធ្វើវិសោធនកម្មដ៏មានសារៈសំខាន់នេះ មានទិសដៅបើកផ្លូវឱ្យមានការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធនឹងការដកសញ្ជាតិ ដើម្បីពង្រឹងការរក្សាការពារសន្តិភាព

និងស្ថិរភាពប្រទេសជាតិ ដាក់ទោសចំពោះបុគ្គលណាដែលធ្វើសកម្មភាពប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខ ផលប្រយោជន៍ជាតិនិងប្រជាជន និងបម្រើផលប្រយោជន៍ឱ្យបរទេស។ ឯកឧត្តមបានបន្ថែមថា នៅក្នុងបណ្តាប្រទេសសមាជិកអង្គការសហប្រជាជាតិ ប្រទេសចំនួន១៥៤ ដែលក្នុងចំនួននេះ ប្រទេសអាស៊ានចំនួន៩ មានច្បាប់នេះរួចទៅហើយ លើកលែងតែកម្ពុជាមួយប៉ុណ្ណោះ។

ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងប្រឈមមុខនាពេលបច្ចុប្បន្ន **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋនៅគ្រប់ស្រទាប់វណ្ណៈទាំងអស់បន្តលើកកម្ពស់ស្មារតីសាមគ្គីភាព ឯកភាពជាតិ រួមគ្នាជាធ្លុងមួយជាមួយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងរាជរដ្ឋាភិបាល ដែលមាន សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជាប្រមុខ វាយបំបាក់ការឈ្លានពានលើបូរណភាពដែនដីកម្ពុជា ពីសំណាក់ប្រទេសថៃ ការពារសន្តិភាពដែលបានមកដោយលំបាក តាមរយៈការធ្វើពលិកម្មដ៏ថ្លៃថ្លារបស់**សម្តេចតេជោ** ដើម្បីវិបុលភាព និងការអភិវឌ្ឍជាតិមាតុភូមិកម្ពុជាឱ្យមានការរីកចម្រើនលើគ្រប់វិស័យ។ **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** បានសង្កត់ធ្ងន់ថា «គ្មានអ្នកណាមកស្រឡាញ់ខ្មែរ ជាងខ្មែរនោះទេ ហើយក៏គ្មានបរទេសណាមកស្រឡាញ់ខ្មែរដូចខ្មែរស្រឡាញ់ខ្មែរនោះដែរ»។

ក្រៅពីសំណេះសំណាល **ឯកឧត្តមប្រធានក្រុមភូមិភាគទី២** និងសមាជិក សមាជិកាក្រុមការងារព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញសួរសុខទុក្ខក្រុមគ្រួសារនិងគោរពវិញ្ញាណក្ខន្ធសពលោកព្រឹន្ទបាលទោ **ផៃ វ័ន្ត** បម្រើការនៅកងពលតូចអន្តរាគមន៍លេខ៩ វរសេនាតូចអន្តរាគមន៍លេខ៣៩៤ កងទ័ពជើងគោក ស្ថិតនៅភូមិក្តុលកណ្តាល ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងសពលោកអនុសេនីយ៍ត្រី **ភាព សោភ័ណ** វរសេនាតូចអន្តរាគមន៍ស្វ័យ? 

វរសេនាធំវិស្វកម្មទី១ ខេត្តកំពង់ចាម នៅភូមិបែកអន្លង់២ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញប្រគល់ថវិកាជូនក្រុមគ្រួសារសព លោកព្រឹន្ទបាលទោ ផៃ វ័ន្ត*



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញប្រគល់ថវិកាជូនក្រុមគ្រួសារសព អនុសេនីយ៍ត្រី ភាព សោភ័ណ*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសួរសុខទុក្ខវីរយុទ្ធជនរងរបួសក្នុងពេលប្រយុទ្ធជាមួយកងទ័ពឈ្លានពានថៃ នៅតាមមន្ទីរពេទ្យជាតិចំនួន៤ ក្នុងរាជធានីភ្នំពេញ





*ឯកឧត្តម អ៊ុច បូររិទ្ធ ចុះសួរសុខទុក្ខវីរយុទ្ធជនរងរបួស នៅមន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះកេតុមាលា*

វីរយុទ្ធជនចំនួន៤០នាក់ ដែលរងរបួសក្នុងពេលប្រយុទ្ធជាមួយកងទ័ពឈ្លានពានថៃ ត្រូវបានឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញសួរសុខទុក្ខនៅតាមមន្ទីរពេទ្យជាតិចំនួន៤ ក្នុងរាជធានីភ្នំពេញ រួមមាន មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះកេតុមាលា នាព្រឹកថ្ងៃអង្គារ ទី៥ ខែសីហា ឆ្នាំ២០២៥។

អញ្ជើញរួមដំណើរក្នុងឱកាសនោះ រួមមាន ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា លោកអ្នកឧកញ៉ាបណ្ឌិត **ទ្រី ភាព** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា ក្រុមទីប្រឹក្សាឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

មានប្រសាសន៍ក្នុងឱកាសចុះសួរសុខទុក្ខ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានពាំនាំការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់បងប្អូនវីរយុទ្ធជនរបស់យើងទាំងអស់ ដែលបាននិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យទាំង៤ ព្រមទាំងបានជូនពរសូមឱ្យឆាប់ជាសះស្បើយ មានសុខភាពល្អឡើងវិញ និងទទួលបានជ័យជម្នះថ្មីៗថែមទៀត នៅក្នុងការបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុការពារជាតិមាតុភូមិ។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានសម្តែងនូវមោទនភាពជាតិខ្ពស់និងសម្តែងនូវការគោរពចំពោះវីរភាពដ៏អង់អាចក្លាហានរបស់វីរយុទ្ធជនយើង ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ក៏ដូចជាវីរយុទ្ធជនកំពុងឈរជើងនៅតាមសមរភូមិមុខ ដែលតស៊ូ អត់ធ្មត់ ក្រាញនៀលប្រយុទ្ធការពារបូរណភាពដែនដីនិងមាតុភូមិកម្ពុជា ប្រឆាំងនឹងការឈ្លានពានយ៉ាងងងើលបំផុតរបស់ពួកសៀម។

នៅក្នុងឱកាសនោះដែរ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានផ្តល់ថវិកា និងអំណោយជាសម្ភារៈមួយចំនួន ជូនដល់វីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាលនៅគ្រប់មន្ទីរពេទ្យនៅរាជធានីភ្នំពេញ ដែលជាសក្ខីភាពបង្ហាញពីមនោសញ្ចេតនាជាភាតរៈ រួមសុខ រួមទុក្ខជាមួយបងប្អូនវីរយុទ្ធជនជាទីគោរព។

ជាការឆ្លើយតប វីរយុទ្ធជនរបស់យើងបានសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសមានចិត្តដ៏ថ្លៃថ្លាបំផុតរបស់ **សម្តេចតេជោ** ដែលជានិច្ចកាលតែងតែផ្សារភ្ជាប់ជាមួយនឹងវីរយុទ្ធជននៅគ្រប់កាលៈទេសៈនិងបានបំពេញតួនាទីដឹកនាំប្រទេសជាតិដ៏ឧត្តុង្គឧត្តម ពោរពេញទៅដោយវីរភាពអង់អាចក្លាហាន ជាពុម្ពគំរូសម្រាប់វីរយុទ្ធជន និងប្រជាពលរដ្ឋគ្រប់រូបនៅទូទាំងប្រទេស សមស្របតាមពាក្យស្លោក «ជីវិតជូនជាតិ អដ្ឋិធាតុជូនគ្រួសារ»។

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសួរសុខទុក្ខ និងនាំយកអំណោយជូនកងពលតូចអន្តរាគមន៍លេខ៨ និងទីបញ្ជាការអន្តរាគមន៍ទួល៩៥ និងចុះសួរសុខទុក្ខវីរយុទ្ធជនកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប

នៅរសៀលថ្ងៃពុធ ទី៦ ខែសីហា ឆ្នាំ២០២៥ គណៈប្រតិភូព្រឹទ្ធសភាដឹកនាំដោយ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់មួយចំនួន ដើម្បីប្រគល់ជូនដល់កងពលតូចអន្តរាគមន៍លេខ៨ និងទីបញ្ជាការអន្តរាគមន៍ទួល៩៥ នៅសាលាខេត្តសៀមរាប និងបានចុះសួរសុខទុក្ខវីរយុទ្ធជនរងរបួសចំនួន៣០នាក់ ក្នុងពេលប្រយុទ្ធជាមួយកងទ័ពឈ្លានពានថៃ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប។



ឯកឧត្តម អ៊ុច បូររិទ្ធ នាំយកអំណោយជូនដល់កងពលតូចអន្តរាគមន៍លេខ៨

ក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខនិងប្រសិទ្ធពរជ័យរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់វីរយុទ្ធជនដែលកំពុងឈរជើងយ៉ាងរឹងមាំនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃនិងវីរយុទ្ធជនដែលកំពុងសម្រាកព្យាបាលស្នាមរបួសដែលបង្កឡើងដោយសកម្មភាពឈ្លានពានយ៉ាងគឃ្លើន ព្រៃផ្សៃ ថោកទាបរបស់កងទ័ពថៃ មកលើបូរណភាពដែនដីកម្ពុជា។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានវាយតម្លៃខ្ពស់ និងសម្តែងនូវគារវកិច្ចគោរពចំពោះវីរភាពដ៏អង់អាចក្លាហានមោះមុតរបស់វីរយុទ្ធជន ដែលបាននិងកំពុងលះបង់កម្លាំងកាយ ចិត្ត បូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុការពារជាតិមាតុភូមិកម្ពុជា ព្រមទាំងបានបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី សូមតាមអភិបាលបោះព្រំឃុំគ្រងថែរក្សា និងប្រសិទ្ធពរជ័យជូនដល់វីរយុទ្ធជនដែលរងរបួសសូមឱ្យបានឆាប់ជាសះស្បើយ និងវីរយុទ្ធជនក្នុងសមរភូមិជួរមុខដ៏អង់អាចក្លាហាននៅតាមព្រំដែន សូមជួបតែសុខសុវត្ថិភាព និងទទួលបានជ័យជម្នះលើសមរភូមិ កម្ចាត់បច្ចាមិត្តឈ្លានពានឱ្យវិនាសអន្តរាយ។

ឆ្លើយតបទៅនឹងទឹកចិត្តដ៏ប្រពៃថ្លៃថ្លាបំផុតរបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា**និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងគណៈប្រតិភូព្រឹទ្ធសភា តំណាងអង្គភាពទាំងពីរនិងវីរយុទ្ធជនដែលកំពុងសម្រាកព្យាបាលជំងឺ បានសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសមានចិត្តដ៏បរិសុទ្ធថ្លៃថ្លាមិនអាចកាត់ថ្លៃបានរបស់ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជានិច្ចកាលតែងតែផ្សារភ្ជាប់ជាមួយនឹងវីរយុទ្ធជននៅតាមសមរភូមិមុខ ក៏ដូចជាប្រជាជននៅទូទាំងប្រទេស និងប្តេជ្ញាដាច់ខាតវាយឱ្យបរាជ័យរាល់ការប៉ុនប៉ងរំលោភឈ្លានពានរបស់ថៃមកលើដែនអធិបតេយ្យកម្ពុជា៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសួរសុខទុក្ខវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប

# ឯកឧត្តម អ៊ុច បូរិទ្ធ៖ ក្នុងកាលៈទេសៈដ៏លំបាកនេះ មានតែថ្នាក់ដឹកនាំប្រទេសជាតិរបស់យើងទើបយល់ច្បាស់អំពីទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋ




*ឯកឧត្តម អ៊ុច បូរិទ្ធ ចុះសួរសុខទុក្ខ និងនាំយកអំណោយជូនប្រជាជនភៀសសឹកមកពីតំបន់នានាតាមបណ្តោយព្រំដែន*

ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានគូសបញ្ជាក់ប្រាប់ជនភៀសសឹក នៅមណ្ឌលសុវត្ថិភាពវត្តសុវណ្ណគិរី ថា នៅក្នុងកាលៈទេសៈដ៏លំបាកនេះ មានតែថ្នាក់ដឹកនាំប្រទេសជាតិរបស់យើងទេ ដែលយល់ច្បាស់អំពីទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋ ដែលត្រូវបង្ខំចិត្តចាកចោលផ្ទះសំបែង ភូមិដ្ឋាន ទ្រព្យសម្បត្តិ សត្វពាហនៈ និងមុខរបរ អាជីវកម្មផ្សេងៗ ដោយសារតែផលប៉ះពាល់ដែលកើតចេញពីការបង្កសង្គ្រាមឈ្លានពានយ៉ាងគឃ្លើន និងសាហាវព្រៃផ្សៃបំផុតរបស់កងទ័ពថៃមកលើមាតុភូមិកម្ពុជាយើង។ ទុក្ខលំបាករបស់បងប្អូន គឺជាទុក្ខលំបាករបស់ថ្នាក់ដឹកនាំនិងប្រជាពលរដ្ឋយើងទាំងអស់នៅទូទាំងប្រទេស ដែលស្តែងចេញតាមរយៈការសម្តែងនូវការគាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈជួយដល់បងប្អូនដែលមានឈាមជ័រពូជពង្សតែមួយ គឺខ្មែរ។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានគូសបញ្ជាក់យ៉ាងដូច្នេះក្នុងឱកាសដែលឯកឧត្តមអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ និង





*ឯកឧត្តម អ៊ុច បូរិទ្ធ ចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារៈប្រើប្រាស់ផ្សេងៗ ជូនប្រជាជនភៀសសឹកមកពីតំបន់នានាតាមបណ្តោយព្រំដែន*

សម្ភារៈប្រើប្រាស់ផ្សេងៗ ជូនប្រជាជនភៀសសឹកមកពីតំបន់នានាតាមបណ្តោយព្រំដែនចំនួន៣៧៤គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសុវត្ថិភាព វត្តសុវណ្ណគិរី (ហៅវត្តឆែប) ស្ថិតនៅភូមិឆែបលិច ឃុំឆែបមួយ ស្រុកឆែប ខេត្តព្រះវិហារ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី៧ ខែសីហា ឆ្នាំ២០២៥។

នៅក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានពាំនាំមកជាមួយបណ្តាំសួរសុខទុក្ខរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដែលលោកទាំងពីរតែងតែគិតគូរជានិច្ចអំពីសុខទុក្ខ និងជីវភាពរស់នៅរបស់បង ប្អូន អ៊ុំ ពូ មីង ក្មួយៗ និងចៅៗទាំងអស់ ដែលជាជនភៀសសឹក ក៏ដូចជាវីរយុទ្ធជននៅគ្រប់ទីកន្លែង និយាយជារួមនិងនិយាយដោយឡែកនៅក្នុងខេត្តព្រះវិហារ។

តាងនាមឱ្យគណៈប្រតិភូព្រឹទ្ធសភា **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានសម្តែងមោទនភាពជាតិខ្ពស់ ចំពោះស្មារតីស្នេហាជាតិរបស់បងប្អូនខ្មែរទាំងក្នុងនិងក្រៅប្រទេស ដែលបានសម្តែងឱ្យឃើញនូវកម្លាំងមហាសាមគ្គីឯកភាពជាតិគាំទ្រចំពោះវីរភាពដ៏អង់អាចក្លាហានរបស់វីរយុទ្ធជនយើងក្នុងការវាយបំបាក់អំពើឈ្លានពានរបស់កងទ័ពថៃ មកលើបូរណភាពដែនដីកម្ពុជា។ ឯកឧត្តម ក៏បានអំពាវនាវឱ្យបងប្អូនយើងទាំងអស់គ្នា ទាំងសមរភូមិមុខនិងសមរភូមិក្រោយ បន្តរួមគ្នាធ្វើពលិកម្ម រែកពុន ប្រឹងប្រែង តស៊ូ និងជម្នះរាល់ឧបសគ្គ ដើម្បីប្រែក្លាយទុក្ខលំបាកអស់ទាំងនេះ ជាកម្លាំងសាមគ្គី ឯកភាពជាតិដ៏រឹងមាំ ពួតដៃជុំវិញរាជរដ្ឋាភិបាល ដែលមានសម្តេចធិបតី **ហ៊ុន ម៉ាណែត** ជាប្រមុខការពារប្រទេសជាតិមាតុភូមិ។

តាមរយៈបងប្អូនជនភៀសសឹកដែលកំពុងស្នាក់នៅមណ្ឌលសុវត្ថិភាព **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា**បានផ្តាំផ្ញើការសាកសួរសុខទុក្ខជូនចំពោះវីរយុទ្ធជនដែលត្រូវជាសាច់ញាតិក្រុមគ្រួសារដែលកំពុងឈរជើងយ៉ាងរឹងមាំនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ប្រកបដោយភាពអង់អាចក្លាហានមោះមុត ដើម្បីបុព្វហេតុការពារជាតិមាតុភូមិកម្ពុជា និងបានបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមតាមជួយថែរក្សាការពារវីរយុទ្ធជន សូមឱ្យមានសុខភាពល្អ សុខសុវត្ថិភាព និងទទួលបានជោគជ័យ ក្នុងការវាយបំបាក់សត្រូវឈ្លានពាននៅគ្រប់សមរភូមិ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងពិធីចុះសួរសុខទុក្ខប្រជាជនភៀសសឹកមកពីតំបន់នានាតាមបណ្តោយព្រំដែន*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយ ជូនវីរយុទ្ធជន និងជនភៀសសឹក នៅខេត្តឧត្តរមានជ័យ

នៅព្រឹកថ្ងៃអាទិត្យ ទី២៤ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ថ្នាំពេទ្យ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ជូនតំណាងវីរយុទ្ធជនការពារប្រាសាទតាមាន់ វីរយុទ្ធជនការពារប្រាសាទតាក្របី មន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ នៅក្នុងបរិវេណសាលាខេត្តឧត្តរមានជ័យ ព្រមទាំងជនភៀសសឹកចំនួន ២៦៧គ្រួសារ ដែលកំពុងស្នាក់បណ្ដោះអាសន្ននៅមណ្ឌលសុវត្ថិភាពស្ថិតក្នុងវត្តភ្នំកំបោរ ភូមិគាប ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

មានប្រសាសន៍សំណេះសំណាលដាច់ដោយឡែកពីគ្នា ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា បាននាំនាំការផ្ដាំផ្ញើសាកសួរសុខទុក្ខនិងពរជ័យរបស់ **សម្ដេចតេជោ** ប្រមុខរដ្ឋស្ដីទី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ជូនដល់វីរយុទ្ធជនដែលកំពុងឈរជើងយ៉ាងរឹងមាំនៅគ្រប់ទីកន្លែងនិយាយជារួមនិងនិយាយដោយឡែកនៅក្នុងខេត្តឧត្តរមានជ័យ និងបងប្អូន អ៊ំ ពូ មីង ក្មួយៗ និងចៅៗជាជនភៀសសឹកទាំងអស់ដែលកំពុងស្នាក់នៅក្នុងវត្តភ្នំកំបោរ ដែលទទួលបានការយកចិត្តទុកដាក់ថែទាំយ៉ាងម៉ត់ចត់ពីសំណាក់អាជ្ញាធរខេត្តឧត្តរមានជ័យ។



*ឯកឧត្តម អ៊ុច បូររិទ្ធ នាំយកអំណោយជូនមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ*

**ឯកឧត្តមប្រធានស្ដីទី** បានវាយតម្លៃខ្ពស់និងសម្ដែងនូវគារវកិច្ចគោរពចំពោះវីរភាពដ៏អង់អាចក្លាហានមោះមុតរបស់វីរយុទ្ធជនដែលបាននិងកំពុងលះបង់កម្លាំងកាយចិត្ត បូជាអាយុជីវិត តស៊ូ អត់ធ្មត់ ក្រាញននៀល ក្នុងការការពារជាតិមាតុភូមិកម្ពុជា និងបានសម្ដែងនូវមោទនភាពជាតិខ្ពស់ចំពោះស្មារតីស្នេហាជាតិរបស់បងប្អូនជនរួមជាតិទាំងអស់ទាំង





*ឯកឧត្តម អ៊ុច បូររិទ្ធ នាំយកអំណោយជូនតំណាងវីរយុទ្ធជនការពារប្រាសាទតាមាន់ វីរយុទ្ធជនការពារប្រាសាទតាក្របី នៅសាលាខេត្តឧត្តរមានជ័យ*

ក្នុង និងក្រៅប្រទេស ដែលបានសម្តែងឱ្យឃើញនូវកម្លាំងមហាសាមគ្គីឯកភាពជាតិជាធ្លុងមួយដើម្បីបុព្វហេតុជាតិមាតុភូមិ វាយបំបាក់អំពើឈ្លានពានរបស់កងទ័ពថៃ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងវៃឆ្លាតរបស់**សម្តេចតេជោ ប្រធានព្រឹទ្ធសភា** និងសម្តេចធិបតី **ហ៊ុន ម៉ាណែត** ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមគ្នានេះ ជាមួយនឹងការសម្តែងនូវមនោសញ្ចេតនាភាតរៈ រួមសុខរួមទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋភៀសសឹក និងការប្តេជ្ញារួមចំណែកជួយឧបត្ថម្ភគាំទ្រដល់បងប្អូននៅក្នុងកាលៈទេសៈដ៏លំបាកនេះ **ឯកឧត្តមប្រធានស្តីទី** បានគូសបញ្ជាក់ថា «ទុក្ខលំបាករបស់បងប្អូន គឺជាទុក្ខលំបាករបស់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋយើងទាំងអស់នៅទូទាំងប្រទេស»។ «សុច្ឆន្ទៈ និងការប្តេជ្ញារបស់កម្ពុជាក្នុងការរក្សាការពារសុខសន្តិភាព មិនមែនបានន័យថា កម្ពុជាសុខចិត្តសម្បទានខឿនឯករាជ្យ អធិបតេយ្យ និងបូរណភាពដែនដីនោះទេ តែជាការប្តេជ្ញាដាច់ខាតរបស់បងប្អូននៅក្នុងទូទាំងប្រទេសរួមសាមគ្គីឯកភាពជាតិជាធ្លុងមួយការពារទឹកដីមាតុភូមិមិនឱ្យបាត់បង់ សូម្បីតែមួយមីល្លីម៉ែត្រ»។

ជាចុងក្រោយ **ឯកឧត្តមប្រធានស្តីទី** បានបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យ គុណកែវទាំងបី សូមតាមអភិបាលប្រោះព្រំ ឃុំគ្រងថែរក្សា និងប្រសិទ្ធពរជ័យសិរិសួស្តី ជូនវីរយុទ្ធជនក្នុងសមរភូមិដ៏អង់អាចក្លាហាននៅតាមព្រំដែនទទួលបានជ័យជម្នះលើសមរភូមិ កម្ចាត់បច្ចាមិត្តឈ្លានពានឱ្យវិនាសន្តរាយឱ្យខាងតែបាន និងជូនដល់បងប្អូនប្រជាជនភៀសសឹក សូមប្រកបតែសុខសុវត្ថិភាព និងសុខភាពល្អ។

ឆ្លើយតបទៅនឹងទឹកចិត្តដ៏ប្រពៃថ្លៃថ្លាបំផុតរបស់**សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងគណៈប្រតិភូព្រឹទ្ធសភា តំណាងវីរយុទ្ធជននៅសមរភូមិ និងតំណាងអាជ្ញាធរខេត្តឧត្តរមានជ័យ ព្រមទាំងបងប្អូនប្រជាជនភៀសសឹក



បានសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសមានចិត្តដ៏បរិសុទ្ធថ្លៃថ្លាមិនអាចកាត់ថ្លៃបានរបស់ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជានិច្ចកាលតែងតែផ្សារភ្ជាប់ជាមួយនឹងវីរយុទ្ធជននៅតាមសមរភូមិមុខ ក៏ដូចជាប្រជាជននៅទូទាំងប្រទេស និងប្តេជ្ញាដាច់ខាតវាយឱ្យបរាជ័យរាល់ការប៉ុនប៉ងរំលោភឈ្លានពានរបស់ថៃមកលើដែនអធិបតេយ្យកម្ពុជា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន







*ឯកឧត្តម អ៊ុច បូរិទ្ធ ចុះសួរសុខទុក្ខ និងនាំយកអំណោយជូនតំណាងវីរយុទ្ធជន ក្នុងខេត្តឧត្តរមានជ័យ*

# ឯកឧត្តម អ៊ុច បូររិទ្ធ អនុញ្ញាតឱ្យនិស្សិតទទួលបានអាហារូបករណ៍ទៅសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃចន្ទ ទី១៨ ខែសីហា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអនុញ្ញាតឱ្យគណៈប្រតិភូសមាគមនិស្សិតកម្ពុជាប្រចាំប្រទេសចិន ដែលបានដឹកនាំនិស្សិតទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសចិន សម្រាប់ឆ្នាំសិក្សា២០២៥ ចំនួន១០០នាក់ ចូលជួបសម្តែងការគួរសម ជម្រាបលា និងទទួលយកអនុសាសន៍ដ៏ខ្ពង់ខ្ពស់។



ឯកឧត្តម អ៊ុច បូររិទ្ធ អនុញ្ញាតឱ្យនិស្សិតទទួលបានអាហារូបករណ៍ទៅសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម

ជាមួយនឹងការទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះនិស្សិតដែលបានទទួលអាហារូបករណ៍ទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានថ្លែងអំណរគុណដល់ឯកឧត្តម **អ៊ុំ ឧុទ្ធទី** ប្រធានក្រុមប្រឹក្សាភិបាលសមាគមនិស្សិតកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិននិងជាជំនួយការសម្តេចតេជោប្រធានព្រឹទ្ធសភា ដែលបានខិតខំប្រឹងប្រែងជួយរកអាហារូបករណ៍ផ្តល់ដល់ក្មួយៗនិស្សិតទៅបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ដែលជាការរួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស សមស្របតាមអាទិភាពទាំងប្រាំក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយថាមពលនិងឈ្លាសវៃរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**។ ជាមួយគ្នានេះ ឯកឧត្តមក៏បានធ្វើការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះស្មារតីសាមគ្គី ឯកភាព និងស្នេហាជាតិ របស់សមាគមនិស្សិតកម្ពុជាប្រចាំប្រទេសចិន តាមរយៈសកម្មភាពរៃអង្គាសថវិកាដើម្បីជួយឧបត្ថម្ភគាំទ្រដល់វីរយុទ្ធជននៅសមរភូមិមុខនិងជនភៀសសឹក ដែលរងគ្រោះដោយសារការឈ្លានពានរបស់កងទ័ពថៃ។

ក្នុងឱកាសនោះ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានផ្តល់អនុសាសន៍ណែនាំដល់និស្សិតទាំងអស់ឱ្យប្រកាន់យកនូវគោលជំហរ «អំណត់ តស៊ូ ព្យាយាម» រៀនសូត្រដែលជាអាវុធដ៏មុតស្រួចដើម្បីអនាគតដ៏ភ្លឺស្វាងរបស់ខ្លួនម្នាក់ៗ និងដើម្បីប្រែក្លាយខ្លួនជា «ទំពាំងស្នងឫស្សី» ដ៏រឹងមាំសម្រាប់ប្រទេសជាតិ ។ ឯកឧត្តមក៏បានណែនាំឱ្យក្មួយៗនិស្សិតទាំងអស់ត្រូវចេះសាមគ្គី ស្រលាញ់រាប់អាន និងចេះយកអាសាគ្នាទៅវិញទៅមក ជ្រោងខ្ពស់ប្រពៃណីវប្បធម៌និងកិត្តិយសជាតិ និងពង្រឹងពង្រីកចំណងមិត្តភាពជាមួយបណ្តានិស្សិតម្ចាស់ផ្ទះ និងបរទេសដែលទៅសិក្សាជាមួយគ្នា។



ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញមានប្រសាសន៍សំណេះសំណាល

នៅចុងបញ្ចប់នៃកម្មវិធី **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានផ្តល់ជូនលិខិតថ្លែងអំណរគុណ ជូនសមាគម









*ទិដ្ឋភាពក្នុងពិធីសម្ដែងការគួរសម*

និស្សិតកម្ពុជាប្រចាំប្រទេសចិន ព្រមទាំងសប្បុរសជនជាតិនិងអន្តរជាតិ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនប្រកបដោយក្តីសប្បុរស និងសមានចិត្តទូលំទូលាយ ឧបត្ថម្ភគាំទ្រដល់វីរកងទ័ពក្លាហានកម្ពុជាដែលឈរជើងនៅជួរមុខទប់ទល់ការឈ្លានពានរបស់កងទ័ពថៃនិងដល់ជនរួមជាតិខ្មែរដែលរងគ្រោះពីការឈ្លានពាន៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូសមាគមនិស្សិតកម្ពុជាប្រចាំប្រទេសចិន និងទស្សនកិច្ចក្នុងសាលអគារក្រហម*

# ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា៖ កម្ពុជាសូមស្វាគមន៍អ្នកសង្កេតការណ៍អន្តរជាតិ និងថៃមកកាន់តំបន់ជម្លោះ ដើម្បីធានាតម្លាភាព និងអនុញ្ញាតឱ្យពិភពលោកបានឃើញការពិត

នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃអង្គការសង្គ្រោះវេជ្ជសាស្ត្រអន្តរជាតិប្រចាំនៅកម្ពុជា (IMR) និងសមាជិកក្រុមប្រឹក្សាសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ នៅវត្តឥន្ទពិសី សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ ក្នុងនាមសមាជិកព្រឹទ្ធសភាកម្ពុជានិងប្រជាជនកម្ពុជា **ឯកឧត្តមបណ្ឌិត**បានថ្លែងអំណរគុណចំពោះលោកស្រី Shauna King ស្ថាបនិក IMR និងសមាជិកក្រុម IMR ទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ចុះពិនិត្យនិងព្យាបាលជំងឺជូនប្រជាពលរដ្ឋ។ ឯកឧត្តមក៏បានថ្លែងថា កម្ពុជាពិតជាមានសំណាងក្នុងចំណោមប្រទេសទាំង៩០ ដែល IMR ផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃ ប្រកបដោយប្រសិទ្ធភាព។




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និងសមាជិកក្រុមប្រឹក្សាសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ*

ជាមួយគ្នានោះដែរ **ឯកឧត្តមបណ្ឌិត** បានលើកសំណើចំពោះ IMR ចំនួនពីរ ដូចខាងក្រោម៖

**១-សូមផ្តោតបេសកកម្មបន្ទាប់ទៅលើសហគមន៍ងាយរងគ្រោះនៅក្នុងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។**

**២-កំណត់គោលដៅពិនិត្យនិងព្យាបាលអ្នកជំងឺឱ្យបានដល់អ្នកទី១.០០០.០០០ ក្នុងខេត្តព្រះវិហារ ដែលមានប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។**

**ឯកឧត្តមបណ្ឌិត** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកប្រធានាធិបតី Donald Trump នូវគំនិតផ្តួចផ្តើមប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា ដែលបានសម្របសម្រួលឱ្យមានបទឈប់បាញ់បន្ទាន់ដោយឥតលក្ខខណ្ឌរវាងកម្ពុជានិងថៃ។ ទន្ទឹមនឹងនោះដែរ ឯកឧត្តមក៏សូមថ្លែងអំណរគុណចំពោះមេដឹកនាំនិងប្រជាជន នៃប្រទេសម៉ាឡេស៊ីនិងចិន សម្រាប់ការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការធានាបទឈប់បាញ់ ក្នុងការលើកកម្ពស់ដំណោះស្រាយដោយសន្តិវិធីនិងការគោរពច្បាប់អន្តរជាតិ។

**ឯកឧត្តមបណ្ឌិត** ក៏បានលើកឡើងថា កម្ពុជាសូមស្វាគមន៍យ៉ាងកក់ក្តៅ នូវអ្នកសង្កេតការណ៍អន្តរជាតិ និងថៃ មកកាន់តំបន់ជម្លោះ ដើម្បីធានាតម្លាភាពនិងអនុញ្ញាតឱ្យពិភពលោកបានឃើញការពិត។

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា
រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមបណ្ឌិត ឆន់ វឌ្ឍនា៖ អាជ្ញាធរគួរជំរុញប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនឱ្យមានការផលិតចំណីអាហារឱ្យបានច្រើន និងប្រកបដោយគុណភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក

ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ ព្រឹទ្ធសភា បានផ្តល់អនុសាសន៍ដល់អាជ្ញាធរស្រុករលាប្អៀរ គួរជំរុញប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ពង្រីកការផលិតចំណីអាហារឱ្យបានច្រើននិងមានគុណភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ស្របពេលដែលប្រជាជនយើងទទួលបានការចាប់អារម្មណ៍ និងគាំទ្រខ្លាំងលើផលិតផលក្នុងស្រុក។ ខេត្តកំពង់ឆ្នាំង គឺជាខេត្តសម្បូកត្រីដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា មានអំណោយផលនៃភូមិសាស្ត្រខេត្តនេះជាប់នឹងបឹងទន្លេសាប។



*ឯកឧត្តមបណ្ឌិត ឆន់ វឌ្ឍនា ជួបសំណេះសំណាល ជាមួយសមាជិកក្រុមប្រឹក្សាឃុំភ្នំក្រាំងដីមាស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង*

**ឯកឧត្តមបណ្ឌិត** បានលើកជាអនុសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសដែលឯកឧត្តមអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំភ្នំក្រាំងដីមាស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដើម្បីឈ្វេងយល់អំពីលទ្ធផលការងារបញ្ហាប្រឈម សំណូមពរ និងទិសដៅការងារបន្តរបស់រដ្ឋបាលឃុំ នៅសាលាឃុំភ្នំក្រាំងដីមាស នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។

**ឯកឧត្តមបណ្ឌិត**បានផ្តាំផ្ញើថា ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសយើងប្រកបដោយចីរភាព គឺយើងត្រូវគិតគូរលើកត្តាបីសំខាន់ៗ៖ ទី១-កត្តាសុខភាព គឺយើងត្រូវចេះរបៀបហូប ដើម្បីទទួលបានសុខភាពល្អ (ហូបតិចៗ ប៉ុន្តែច្រើនមុខ) ទី២-កត្តាសមត្ថភាព គឺប្រជាជនយើងត្រូវមានសមត្ថភាពអាចសិក្សា រៀនសូត្របានខ្ពស់ មានសមត្ថភាពអាចរកការងារបានល្អ ប្រាក់ចំណូលខ្ពស់ ហើយដើម្បីអាចសម្រេចបាននូវកត្តាទាំងនេះ គឺប្រជាពលរដ្ឋយើងត្រូវចេះភាសាអង់គ្លេសដែលជាភាសាសម្រាប់ការសិក្សាស្រាវជ្រាវ ការធ្វើជំនួញ និងការប្រាស្រ័យទាក់ទងជាដើម។ ជាក់ស្តែងថ្មីៗនេះ នៅពេលដែល





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

យើងចង់បង្ហាញពិភពលោកថាប្រទេសថៃបានឈ្លានពានមកលើអធិបតេយ្យភាពកម្ពុជាយើង គឺយើងត្រូវប្រើប្រាស់ភាសាអង់គ្លេសជាអាទិភាព។ ហើយទី៣-កត្តាជីវភាព ពេលប្រជាពលរដ្ឋមានជីវភាពធូរធារ នោះសង្គមជាតិក៏មានបានតាមនោះដែរ។





ក្នុងឱកាសនោះផងដែរ **ឯកឧត្តមបណ្ឌិត** បាននាំប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ សម្ដេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលតែងតែយកចិត្តទុកដាក់ជាមួយបងប្អូននៅតាមមូលដ្ឋានជាប្រចាំ និងបានឧបត្ថម្ភថវិកាមួយចំនួនដល់សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកអញ្ជើញចូលរួម ព្រមទាំងផ្ដល់ថវិកាដល់រដ្ឋបាលឃុំ ដើម្បីដាំកូនឈើនៅក្នុងបរិវេណសាលាឃុំដែលទើបសាងសង់ថ្មី។

ក្រៅពីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ **ឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា** បានអញ្ជើញចុះទៅពិនិត្យស្រះចិញ្ចឹមត្រី និងការកែច្នៃត្រីក្នុងខេត្តកំពង់ឆ្នាំង ដើម្បីពិនិត្យលទ្ធភាពក្នុងការពង្រីកទីផ្សារផ្គត់ផ្គង់បន្ថែម ព្រមទាំងបានអញ្ជើញទៅភូមិស្វាយជូនកែវ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដើម្បីគោរពវិញ្ញាណក្ខន្ធ និងឧបត្ថម្ភថវិកាដល់គ្រួសាររបស់លោកវរសេនីយ៍ត្រី **អ៊ួន ហាច** មេបញ្ជាការរងគ៣ វរសេនាតូចលេខ២ កងពលតូចអន្តរាគមន៍លេខ១ ដែលបានពលីជីវិតនៅលើសមរភូមិប្រយុទ្ធ ក្នុងបុព្វហេតុការពារបូរណភាពទឹកដីកម្ពុជាពីកងទ័ពឈ្លានពានថៃ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តមបណ្ឌិត ជន់ ខ្លែនា អញ្ជើញចុះពិនិត្យស្រះចិញ្ចឹមត្រី ការច្នៃត្រី និងការផលិតចំណីអាហារប្រកបដោយគុណភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក*



*ឯកឧត្តមបណ្ឌិត ជន់ ខ្លែនា អញ្ជើញគោរពវិញ្ញាណក្ខន្ធ លោកវរសេនីយ៍ត្រី អ៊ួន ហាច*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** បានអញ្ជើញថ្វាយព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានិងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ យាងទៅពិនិត្យព្រះរាជសុខភាព នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ។



❈នាព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមឧត្តមសេនីយ៍ឯក **ដួង សំនៀង** មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ៧ កងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ ដើម្បីបុព្វហេតុការពារបូរណភាពទឹកដីកម្ពុជា នៅវត្តនិរោធរង្សី សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃចន្ទ ទី២៨ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយគណៈកម្មការទាំង១០នៃព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តរបស់ក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ វិជិត្ត** រដ្ឋលេខាធិការប្រចាំការ អំពីគម្រោងថវិកាឆ្នាំ២០២៦ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខង្សុនា** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អមដំណើរដោយ សមាជិក ព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ និងចែកអំណោយសម្រាលទុក្ខលំបាកប្រជាពលរដ្ឋភៀសសឹក នៅខេត្តឧត្តរមានជ័យ។



❈នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខង្សុនា** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អមដំណើរដោយសមាជិកព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ និងចែកអំណោយសម្រាលទុក្ខលំបាកប្រជាពលរដ្ឋភៀសសឹក ចំនួន៤០០គ្រួសារ នៅខេត្តបន្ទាយមានជ័យ។



❈នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខង្សុនា** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អមដំណើរដោយសមាជិកព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ និងចែកអំណោយសម្រាលទុក្ខលំបាកប្រជាពលរដ្ឋភៀសសឹក ប្រមាណ២០០០០នាក់ នៅវត្តពោធិ៍៥០០០ដើម ស្ថិតក្នុងភូមិគូលែនត្បូង ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញទទួលជួបឯកឧត្តម Shaharuddin Onn ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា និងសិក្សាអំពីលទ្ធភាពបង្កើនកិច្ចសហប្រតិបត្តិការការទូតសភា និងវិស័យផ្សេងៗទៀតរួមមានអប់រំ សុខភាព ទេសចរណ៍ កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម រវាងកម្ពុជា ជាមួយម៉ាឡេស៊ី នៅសាលពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយគណៈកម្មការទាំង១០ និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ នៅសាលពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាថ្ងៃសៅរ៍ ទី៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតឱ្យប្រធានក្រុមហ៊ុន និងសមាគមChuna Yu របស់ចិន ចូលជួបសម្តែងការគួរសម និងប្រគល់អំណោយមនុស្សធម៌ នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុម បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) ចូលរួមគោរពវិញ្ញាណក្ខន្ធលោកវរសេនីយ៍ត្រី **លៀម សំពៅមាស** មន្ត្រីប៉ុស្តិ៍នគរបាលការពារព្រំដែនគោកអានសេះ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៧៩៣ និងលោកអនុសេនីយ៍ឯក **ពោ ខៃ** បម្រើការងារនៅកងពលតូចលេខ៤៨ កងពលធំលេខ៣ នៅសង្កាត់ព្រែកឯង និងសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាល្ងាចថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាជាតិ លើកទី៦០ របស់សាធារណរដ្ឋសិង្ហបុរី នៅសណ្ឋាគារ Raffles Le Royal រាជធានីភ្នំពេញ។




❈នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពី សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុម បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ)ចុះសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភថវិកា និងសម្ភារៈជូន លោកអនុសេនីយ៍ឯក **គុល ចន** អាយុ៥៦ឆ្នាំ និងលោកពលបាលឯក **ស៊ីន សុវណ្ណ** អាយុ២១ឆ្នាំ ឈរជើងប្រាសាទតាក្របី (ខេត្តឧត្តរមានជ័យ) នៅមន្ទីរពេទ្យព្រះអង្គឌួង។




❈នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យឯករាជ្យជាតិ លើកទី៧៩ របស់សាធារណរដ្ឋឥណ្ឌា នៅសណ្ឋាគារ Sofitel Phnom Penh Phokeethra។



❈នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំប្រចាំខែសីហា និងកំណត់ទិសដៅការងារបន្តរបស់ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា៕



# គណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់វិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តព្រះសីហនុ

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) ដឹកនាំដោយឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ ដឹកនាំដោយឯកឧត្តម **ម៉ាង ស៊ីណេត** អភិបាលខេត្ត ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ សក្តានុពលសេដ្ឋកិច្ច ការប្រមូលចំណូល និងកិច្ចការពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលាខេត្តព្រះសីហនុ នាព្រឹកថ្ងៃចន្ទ ទី១១ ខែសីហា ឆ្នាំ២០២៥។



*ឯកឧត្តម យស ផានីត្តា ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា*

នារសៀលថ្ងៃដដែល គណៈប្រតិភូគណៈកម្មការទី២ ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ សក្តានុពលកំពង់ផែ ទិដ្ឋភាពសេដ្ឋកិច្ច បច្ចេកទេស ទិសដៅការងារ និងចក្ខុវិស័យនាពេលអនាគត។

បន្ទាប់មក គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ជំនួយការហិរញ្ញវត្ថុ និងជំនួយការរដ្ឋបាល ក្នុងស្រុកស្ទឹងហាវ នៃខេត្តព្រះសីហនុ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពរនានា ជាពិសេសដើម្បីឈ្វេងយល់អំពីការគ្រប់គ្រងចំណាយចំណូលរបស់ស្រុកស្ទឹងហាវ។

ក្នុងជំនួបនីមួយៗ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បាននាំប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងបានជម្រាបអំពីការរៀបចំនិងដំណើរការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភានីតិកាលទី៥ ព្រមទាំងបានបញ្ជាក់អំពីអាទិភាពចម្បងចំនួនពីរ ដែល**សម្តេចតេជោប្រធានព្រឹទ្ធសភា** យកចិត្តទុកដាក់ខ្ពស់ គឺ «ការទូតសភា» និង «គណនេយ្យភាពក្រុមប្រឹក្សាឃុំ សង្កាត់»។





*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ*




*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ*

បន្ទាប់ពីបានស្តាប់របាយការណ៍និងពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក **ឯកឧត្តមប្រធានគណៈកម្មការ** បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំខេត្តនិងមន្ទីរជំនាញពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញការងារ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបានបម្រើប្រជាពលរដ្ឋបានយ៉ាងល្អ ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ស្របតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរៀងៗខ្លួន។ ទន្ទឹមនឹងនោះ **ឯកឧត្តម**ក៏បានលើកទឹកចិត្តដល់រដ្ឋបាលខេត្ត មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន សូមបន្តយកចិត្តទុកដាក់អនុវត្តការងារ ដើម្បីឱ្យខេត្តកាន់តែមានការរីកចម្រើននិងអភិវឌ្ឍបានយ៉ាងឆាប់រហ័ស។ ចំណែកបញ្ហាប្រឈមដែលខេត្តនិងមន្ទីរបានលើកឡើង គណៈកម្មការទី២ព្រឹទ្ធសភា នឹងជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមប្រធានគណៈកម្មការ**ក៏បានជម្រាបអំពីស្ថានភាពបច្ចុប្បន្ននៅតាមព្រំដែនកម្ពុជា-ថៃ ដែលនៅមានការផុយស្រួយនៅឡើយ ហើយនៅពេលនេះគឺយើងគ្រប់គ្នាត្រូវតែជឿទុកចិត្តទៅលើថ្នាក់ដឹកនាំប្រទេសយើងនិងរួមគ្នាជាធ្លុងដ៏រឹងមាំមួយ ហើយបន្តជួយជ្រោមជ្រែងលើកទឹកចិត្តដល់វីរកងទ័ពដែលនៅសមរភូមិមុខ។ ជាងនេះទៅទៀត ត្រូវបន្តយកចិត្តទុកដាក់ និងអនុវត្តតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ **ហ៊ុន សែន** ក្នុងការខិតខំប្រមូលចំណូលជូនជាតិ ទាំងចំណូលពន្ធដារ ចំណូលគយ និងចំណូលមិនមែនសារពើពន្ធ ព្រមទាំងចំណាយឱ្យចំគោលដៅ និងមានប្រសិទ្ធភាព។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ជួបពិភាក្សាការងារ និងថតរូបអនុស្សាវរីយ៍ជាមួយរដ្ឋបាលស្រុកស្ទឹងហាវ*

# គណៈកម្មការទី២ព្រឹទ្ធសភា ពិភាក្សាការងារជាមួយ ថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នាព្រឹកថ្ងៃទី២០ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៥ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) ដឹកនាំដោយឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរសវនកម្មជាតិ ដឹកនាំដោយលោកជំទាវបណ្ឌិត **សោម គីមសួគ៌** អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិនិងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីស្វែងយល់អំពីវឌ្ឍនភាពការងារ បេសកកម្ម ចក្ខុវិស័យ ឱកាស និងបញ្ហាប្រឈមនានា ជាពិសេសការបង្កើនសហការឱ្យកាន់តែល្អប្រសើរឡើង រវាងគណៈកម្មការទី២ព្រឹទ្ធសភា និងអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។



*ឯកឧត្តម យស ផានីត្តា ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា*

ក្នុងជំនួបពិភាក្សាការងារនីមួយៗ ឯកឧត្តម **យស ផានីត្តា** បានជម្រាបអំពីព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប៉ិនប្រសប់ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានកំណត់អាទិភាពចម្បងចំនួន២ គឺការទូតសភានិងគណនេយ្យភាពជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ព្រមទាំងរចនាសម្ព័ន្ធដឹកនាំរបស់ព្រឹទ្ធសភា។

ក្នុងឱកាសនោះ លោកជំទាវបណ្ឌិត **សោម គីមសួគ៌** និងឯកឧត្តមបណ្ឌិត **គុណ ញឹម** បានជម្រាបជូនអំពីវឌ្ឍនភាពការងារ រចនាសម្ព័ន្ធគ្រប់គ្រង ដឹកនាំ នីតិវិធី បែបបទ ផែនការយុទ្ធសាស្ត្រ កំណែទម្រង់ ការធ្វើទំនើបកម្ម ការបណ្តុះបណ្តាលមន្ត្រីចក្ខុវិស័យនិងបញ្ហាប្រឈម។





*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ*





*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

បន្ទាប់មក គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ជាមួយនឹងថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ នៃស្ថាប័នទាំងពីរ បានពិភាក្សាការងារយ៉ាងផុលផុសពាក់ព័ន្ធនឹងការងារនិងចូលរួមយោបល់កែលម្អសំដៅបង្កើនគុណភាពនិងប្រសិទ្ធភាពការងារ។

តាងនាមឱ្យគណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **យស ផានីត្តា** បានថ្លែងកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃស្ថាប័នទាំងពីរ ដែលបានខិតខំបំពេញការងារ ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ព្រមទាំងសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមប្រធានគណៈកម្មការ** ក៏បានលើកឡើងអំពីស្ថានភាពបច្ចុប្បន្ននៅតាមព្រំដែនកម្ពុជា-ថៃ នៅមានការផុយស្រួយនៅឡើយ ហើយយើងពិតជាឈឺចាប់ចំពោះការឈ្លានពានរបស់ប្រទេសថៃ។ ហេតុដូចនេះក្នុងស្ថានភាពដ៏លំបាកនេះ យើងត្រូវតែរួមកម្លាំងសាមគ្គីគ្នា ជួយជ្រោមជ្រែង និងលើកទឹកចិត្តដល់វីរកងទ័ពដែលនៅសមរភូមិមុខ ក៏ដូចជាការផ្សព្វផ្សាយប្រាប់ដល់ពិភពលោកតាមរយៈបណ្ដាញសង្គមថា ប្រទេសកម្ពុជាមិនត្រូវការសង្គ្រាមគឺត្រូវការសន្តិភាព៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ពិភាក្សាការងារជាមួយ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*



*គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

# គណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយមនុស្សធម៌ជូនប្រជាជនភៀសសឹក នៅក្រុងព្រះវិហារ





*ឯកឧត្តមបណ្ឌិត ចែម វីឌ្យ៉ា ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ចុះសួរសុខទុក្ខប្រជាជនភៀសសឹក នៅខេត្តព្រះវិហារ*

នាព្រឹកថ្ងៃសៅរ៍ ទី៩ ខែសីហា ឆ្នាំ២០២៥ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការ បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ជាគ្រឿងឧបភោគ បរិភោគ ចែកជូនជនភៀសសឹកមកពីតំបន់តាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ចំនួន៤០០គ្រួសារ ដែលកំពុងស្នាក់នៅបណ្ដោះអាសន្នក្នុងមណ្ឌលសុវត្ថិភាព នៅវត្តព្រះពុទ្ធមានជ័យ (ហៅវត្តប៉ាលហាល) សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ។



នៅក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បាននាំប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ សម្ដេចអគ្គមហា





*គណៈកម្មការទី៥ព្រឹទ្ធសភា ចែកអំណោយមនុស្សធម៌ជូនប្រជាជនភៀសសឹក នៅខេត្តព្រះវិហារ*




*គណៈកម្មការទី៥ព្រឹទ្ធសភា ចែកអំណោយមនុស្សធម៌ជូនប្រជាជនភៀសសឹក នៅខេត្តព្រះវិហារ*

សេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ជូនចំពោះបងប្អូនរួមជាតិទាំងអស់ រួមទាំងជនភៀសសឹក និងវីរយុទ្ធជន ដែលកំពុងខិតខំការពារអធិបតេយ្យភាព និងបូរណភាពទឹកដីតទល់នឹងការឈ្លានពានរបស់កងទ័ពថៃ។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ឯកឧត្តម **គឹម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ដែលបានយកចិត្តទុកដាក់និងដឹកនាំការងាររៀបចំបណ្តោះអាសន្នមណ្ឌលសុវត្ថិភាពជូនជនភៀសសឹកមកពីតំបន់នានាតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាច្រើនម៉ឺននាក់បានយ៉ាងល្អ គ្រប់ជ្រុងជ្រោយ និងមានសុវត្ថិភាព។

**ឯកឧត្តមបណ្ឌិត** បានមានប្រសាសន៍ថា ការអញ្ជើញចុះសួរសុខទុក្ខនាឱកាសនេះ គឺក្នុងស្មារតីចូលរួមគាំទ្ររាជរដ្ឋាភិបាល ដឹកនាំដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានជោគជ័យយ៉ាងធំក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងឈប់បាញ់គ្នារវាងកម្ពុជា និងថៃ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ នៅប្រទេសម៉ាឡេស៊ី។ ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល តែងធ្វើការស្អិតល្មួតជាមួយគ្នា ហើយផ្សារខ្លួនជាមួយប្រជាជនយើងទាំងអស់។

ក្រៅពីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញថ្វាយបង្គំព្រះចៅអធិការវត្តព្រះពុទ្ធមានជ័យ (ហៅវត្តប៉ាលហាល) និងបានប្រគេនបច្ច័យបួន គាប់ជួនថ្ងៃនោះជាថ្ងៃសីលពេញបូណ៌មី ១៥កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញថ្វាយបង្គំព្រះចៅអធិការវត្តព្រះពុទ្ធមានជ័យ និងបានប្រគេនបច្ច័យបួន នៅខេត្តព្រះវិហារ*

# គណៈកម្មការទី៦ព្រឹទ្ធសភា ពិភាក្សាការងារជាមួយនឹង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

ក្នុងអំឡុងពេលនៃចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី៣ នីតិកាលទី៥ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២១ ខែសីហា ឆ្នាំ២០២៥ គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា (គណៈកម្មការទី៦) ដឹកនាំដោយលោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងសាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដែលដឹកនាំដោយឯកឧត្តម **សេង ស៊ីវុត្ថា** ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម **អ៊ុក សាវុធ** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ នៅសាលប្រជុំនៃសាលាឧទ្ធរណ៍ភ្នំពេញ។



*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា*

នៅក្នុងជំនួបនៃកិច្ចពិភាក្សាការងារដ៏មានសារសំខាន់នោះ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** បានមានប្រសាសន៍នាំយកនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ព្រឹទ្ធសភា ព្រមទាំងបានគូសបញ្ជាក់អំពីទស្សនវិស័យរបស់ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលជានិច្ចជាកាល **សម្តេច**តែងតែផ្តោតការយកចិត្តទុកដាក់ខ្ពស់គិតគូរអំពីសុខទុក្ខតម្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយតែងតែណែនាំមន្ត្រីទាំងអស់ឱ្យខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការបំពេញភារកិច្ចបម្រើប្រជាពលរដ្ឋប្រកបដោយការទទួលខុសត្រូវនិងភាពស្មោះត្រង់បំផុត។





*គណៈកម្មការទី៦ព្រឹទ្ធសភា ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ*

**លោកជំទាវបណ្ឌិត** បានជម្រាបអំពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បីឈ្វេងយល់និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់និងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋនៅក្នុងអង្គតុលាការជាន់ខ្ពស់។





*គណៈកម្មការទី៦ព្រឹទ្ធសភា ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ*

ក្នុងឱកាសនោះ ឯកឧត្តម **សេង ស៊ីវុត្ថា** និងឯកឧត្តម **អ៊ុក សាវុធ** បានធ្វើសេចក្តីរាយការណ៍ដោយផ្តោតសំខាន់ទៅលើ៖ ទី១-ការអនុវត្តច្បាប់និងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ ទី២-ទិន្នន័យសំណុំរឿងក្តី និងចំណាត់ការ ទី៣-បញ្ហាប្រឈមដែលបានជួបប្រទះ និងទី៤-សំណូមពរ។

ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ឯកឧត្តមប្រធានសាលាឧទ្ធរណ៍និងឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ និងឆ្លងតាមកិច្ចពិភាក្សាយ៉ាងផុលផុសរួចមក លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** បានកោតសរសើរចំពោះថ្នាក់ដឹកនាំនៃសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវាយុត្តិធម៌ ជូនប្រជាពលរដ្ឋប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈកម្មការទី៦ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ*

# គណៈកម្មការទី៨ព្រឹទ្ធសភា សួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក និងពិនិត្យស្ថានភាពពលករធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃវិញ

ពីថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃព្រឹទ្ធសភា (គណៈកម្មការ ទី៨) ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរមានសមត្ថកិច្ច និងពិនិត្យស្ថានភាពនៃការវិលត្រឡប់របស់ប្រជាពលរដ្ឋខ្មែរ នៅតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ច្រកព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង និងច្រកព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន។



*លោកជំទាវ មាន សំអាន សំណេះសំណាលជនភៀសសឹក*

នៅខេត្តបន្ទាយមានជ័យ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា និងមានការយាងអញ្ជើញចូលរួមពីសម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** ឧត្តមប្រឹក្សាផ្ទាល់





*គណៈកម្មការទី៨ព្រឹទ្ធសភា និងសម្តេចរាជបុត្រីព្រះអនុជ ចុះសួរសុខទុក្ខប្រជាជនភៀសសឹក នៅជំរំវត្តច័ន្ទសុីសាមគ្គីតេនារាម ខេត្តបន្ទាយមានជ័យ*

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាជនភៀសសឹកចំនួន ៤៥៨គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្ន នៅជំរំវត្តច័ន្ទសុីសាមគ្គីតេនារាម ស្ថិតក្នុងឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងបន្តចុះទៅពិនិត្យស្ថានភាពនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត។

នៅខេត្តបាត់ដំបង និងខេត្តប៉ៃលិន គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា ត្រូវបានទទួលស្វាគមន៍ពីឯកឧត្តម **សុខ លូ** អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងលោកជំទាវបណ្ឌិត **បាន ស្រីមុំ** អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន ដោយបានចុះពិនិត្យស្ថានភាព និងជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកស្រុកកំណើតវិញ នៅច្រកព្រំដែនអន្តរជាតិដូង និងច្រកព្រំដែនអន្តរជាតិព្រំ។

នៅខេត្តទាំងបី លោកជំទាវ **មាន សំអាន** ប្រធានគណៈប្រតិភូ បាននាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងបានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ តស៊ូ អត់ធ្មត់ ត្រូវជឿទុកចិត្តទៅលើថ្នាក់ដឹកនាំ និងរួមសាមគ្គីគ្នាជាធ្លុងមួយឱ្យបានរឹងមាំ ក្នុងគ្រាដែលប្រទេសជាតិកំពុងជួបប្រទះសង្គ្រាមឈ្លានពានពីថៃ




គណៈកម្មការទី៨ព្រឹទ្ធសភា ចុះពិនិត្យស្ថានភាពនៃការវិលត្រឡប់របស់ប្រជាជនខ្មែរ នៅច្រកទ្វារព្រំដែនអន្តរជាតិដូង

ព្រមទាំងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អាជ្ញាធរ មន្ត្រីជំនាញ កងកម្លាំងប្រដាប់អាវុធ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ប្រចាំការនៅច្រកព្រំដែន ដែលកំពុងសស្រាក់សស្រាំក្នុងការជួយសម្របសម្រួលដំណើរវិលត្រឡប់របស់ពលករខ្មែរ ហើយត្រូវបន្តខិតខំយកចិត្តទុកដាក់បង្កលក្ខណៈងាយស្រួលជូនពួកគាត់ថែមទៀត។




គណៈកម្មការទី៨ព្រឹទ្ធសភា ចុះពិនិត្យស្ថានភាពនៃការវិលត្រឡប់របស់ប្រជាជនខ្មែរ នៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ

ក្រៅពីចុះជួបសំណេះសំណាល គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បាននាំយកសម្ភារៈ ថវិកា អញ្ជើញគោរពវិញ្ញាណក្ខន្ធនិងចូលរួមរំលែកទុក្ខជាមួយគ្រួសារសព លោកនាយចំណង់ **មៀច សុខណាវាធីប** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិប្រាសាទតាក្របី ខេត្តព្រះវិហារ ក្នុងពេលបំពេញបេសកកម្មការពារអធិបតេយ្យ និងបូរណភាពទឹកដី នៅភូមិអូរគគីរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




គណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធ និងចូលរួមរំលែកទុក្ខជាមួយគ្រួសារសព លោកនាយចំណង់ មៀច សុខណាវាធីប នៅខេត្តបាត់ដំបង

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ សំណេះសំណាល ជាមួយអាជ្ញាធរស្រុក ក្រុងទាំង១០ ក្នុងខេត្តកណ្ដាល





*ឯកឧត្តម ម៉ម ប៊ុននាង សំណេះសំណាលជាមួយអាជ្ញាធរស្រុកកោះធំ និងក្រុងសំពៅពូន ខេត្តកណ្ដាល*

នៅថ្ងៃទី១៤ ទី១៩ ទី២២ និងទី២៧ ខែសីហា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្ដាល) ដឹកនាំដោយ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលដាច់ដោយឡែកពីគ្នាជាមួយ ក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅស្រុកស្អាង ស្រុកកោះធំ ក្រុងសំពៅពូន ស្រុកលើកដែក ស្រុកកៀនស្វាយ ស្រុកល្វាឯម ក្រុងអរិយក្សត្រ ស្រុកខ្សាច់កណ្ដាល ស្រុកមុខកំពូល និងស្រុកពញាឮ ខេត្តកណ្ដាល។

នៅគ្រប់ពិធីតាមក្រុង ស្រុក ឯកឧត្តម **ម៉ម ប៊ុននាង** បាននាំនូវប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងបានជម្រាបអំពីគោលបំណងនៃការចុះជួបសំណេះសំណាល គឺដើម្បីផ្សារភ្ជាប់និងរួមប្រាស្រ័យទាក់ទងឱ្យកាន់តែជិតស្និទ្ធជាមួយថ្នាក់ដឹកនាំក្រុង ស្រុក ជាពិសេសអង្គបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងផ្សព្វផ្សាយអំពីលទ្ធផលនៃកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា លើប្រធានបទ «សេដ្ឋកិច្ចក្រៅប្រព័ន្ធ, ប្រព័ន្ធគាំពារសង្គម និងវិស័យកសិកម្ម» និងការវិវត្តនៃស្ថានភាពព្រំដែនកម្ពុជា-ថៃ ព្រមទាំងឈ្វេងយល់អំពីបញ្ហាប្រឈមសំណូមពរនិងវឌ្ឍនភាពនៅក្នុងមូលដ្ឋាន។





*ឯកឧត្តម ប្រាក់ ចំរើន អនុប្រធានក្រុម*

ក្នុងឱកាសនោះផងដែរ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានជម្រាបជូនអង្គពិធីដោយសង្ខេបអំពីដំណើរការប្រព្រឹត្តទៅនៃព្រឹទ្ធសភា នីតិកាលទី៥ និងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ព្រមទាំងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពទាំង៧ចំណុច។

ទន្ទឹមគ្នានោះ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** លេខាធិការក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានផ្សព្វផ្សាយអំពីលទ្ធផលនៃកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា ទាក់ទងនឹងប្រធានបទ «សេដ្ឋកិច្ចក្រៅប្រព័ន្ធ» ដោយបានលើកឡើងអំពីផលប្រយោជន៍និងសារៈសំខាន់នៃការចុះឈ្មោះចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ព្រមទាំងបានគូសបញ្ជាក់ អំពីការរួមស្មារតីគ្នាជាធ្លុងមួយនិងជំរុញឱ្យអាជ្ញាធរទាំងអស់ជួយសម្រួល និងគិតគូរអំពីការផ្ដល់សេវាសាធារណៈការចុះបញ្ជីអត្រានុកូលដ្ឋាន និងជួយរកការងារឱ្យប្រជាពលករ



*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី លេខាធិការក្រុម*

យើងដែលបានវិលត្រឡប់មកពីប្រទេសថៃ។

ជាមួយគ្នានោះ លោកជំទាវ **សួស សារ៉ាម** សមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានធ្វើបទបង្ហាញទាក់ទងនឹងប្រធានបទ «ប្រព័ន្ធគាំពារសង្គម» ដោយបានលើកឡើងអំពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋ ការស្តារជីវភាពរស់នៅប្រចាំថ្ងៃ ដោយផ្តោតលើសន្តិសុខស្បៀង ការផ្តល់សេវាសុខាភិបាល ការអប់រំ សេវាសង្គម និងការកសាងសំណាញ់សុវត្ថិភាពសង្គម។



*លោកជំទាវ សួស សារ៉ាម សមាជិកាក្រុម*

ឆ្លងតាមការពិភាក្សា និងផ្លាស់ប្តូរបទពិសោធគ្នារួចមកឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានក្រុម បានវាយតម្លៃខ្ពស់ចំពោះការខិតខំបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់។ ចំពោះបញ្ហាប្រឈម និងសំណូមពរនានា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានចូលរួមដោះស្រាយនិងគោរពជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីជម្រាបទៅក្រសួងពាក់ព័ន្ធចាត់វិធានការចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

ទន្ទឹមគ្នានោះ **ឯកឧត្តមប្រធានក្រុម** បានជម្រាបជូនអំពីការវិវត្តសភាពការណ៍ថ្មីៗនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាពិសេសភាពអង់អាចក្លាហានរបស់វីរកងទ័ពយើងនិងការរួមចំណែកដ៏ធំធេងរបស់សម្តេចតេជោ **ហ៊ុន សែន** ជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការការពារបូរណភាពទឹកដីនិងដែនអធិបតេយ្យជាតិ ពីការឈ្លានពានរបស់កងទ័ពថៃ និងស្មារតីស្នេហាជាតិ មាតុភូមិនិងសាមគ្គីឯកភាពជាតិជាធ្លុងមួយរបស់បងប្អូនប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈនៅទូទាំងប្រទេស ក្នុងការចូលរួមឧបត្ថម្ភ គាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈ ជួយដល់វីរកងទ័ព និងប្រជាជនភៀសសឹក។

**ឯកឧត្តម**បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ សូមជឿទុកចិត្តលើការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា**និងសម្តេចធិបតី **ហ៊ុន ម៉ាណែត** ក្នុងការការពារទឹកដី មាតុភូមិមិនឱ្យបាត់បង់សូម្បីតែមួយមីល្លីម៉ែត្រឡើយ និងដោះស្រាយវិវាទព្រំប្រទល់ជាមួយប្រទេសថៃដោយសន្តិវិធី ដោយផ្អែកលើច្បាប់ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ដើម្បីនិរន្តរភាពសន្តិភាពសម្រាប់ប្រជាជនទាំងពីរកម្ពុជានិងថៃ។

ក្នុងឱកាសរៀបចំពិធីសំណេះសំណាលនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បាននាំយកអំណោយឧបត្ថម្ភជូនក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំទាំងអស់ ដោយក្នុងម្នាក់ៗទទួលបានភេសជ្ជៈ អំណោយរបស់អង្គការមូលនិធិចែករំលែកសង្គ្រោះជីវិតសកលកូរ៉េ ចំនួន១កញ្ចប់និងថវិកាមួយចំនួន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល និងថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរស្រុកល្វាឯម និងក្រុងអរិយក្សត្រ ខេត្តកណ្តាល*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញជួបសំណេះសំណាល គ្រួសារវីរកងទ័ពពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពាន របស់កងទ័ពថៃ នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តកំពង់ធំ

ពីថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញជួបសំណេះសំណាល និងចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពវីរកងទ័ព ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារនិងខេត្តកំពង់ធំ។



*ឯកឧត្តមបណ្ឌិត នាង ផាត ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨*

នៅស្រុកតាំងគោក និងស្រុកសណ្ដាន់ ខេត្តកំពង់ធំ នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានអញ្ជើញគោរពវិញ្ញាណក្ខន្ធវីរជនការពារព្រំដែន ចំនួន៤រូប គឺ១-លោក **ម៉ូ ផូ** ២-លោក **ពេជ ម៉ៅល** ៣-លោក **ញាត ឈឿន** និង៤-លោក **ចាប ថី**។

ដោយឡែក នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តកំពង់ធំ នាថ្ងៃទី៩ និងទី១០ ខែសីហា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ រួមមាន លោកជំទាវ **ឃួន ឃុនឌី** អនុប្រធានក្រុម លោកជំទាវ **ចឹក ហេង** និងឯកឧត្តម **ញ៉ៀម សាម៉ន** សមាជិកក្រុម តំណាងឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខយ៉ាងក្រៀមក្រំបំផុតជាមួយក្រុមគ្រួសារសពលោកពលបាលឯក **ស៊ីថា រិទ្ធី** ជាយោធិននៃកងពលតូចអន្តរាគមន៍លេខ១២៨ លោកព្រឹន្ទបាលឯក **ស៊ឹម គា** កងពលតូចអន្តរាគមន៍លេខ៨ និងលោកព្រឹន្ទបាលឯក **ឌី សេង** អនុសេនាធំលេខ៣ វរសេនាតូច៣៨២ ។

នៅគ្រប់ពិធី ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បាននាំនូវប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពី**សម្ដេចតេជោ ប្រធានព្រឹទ្ធសភា** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់ក្រុមគ្រួសារសពចំពោះការបាត់បង់ស្វាមី ឪពុក






*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញគោរពវិញ្ញាណក្ខន្ធវីរជនការពារព្រំដែន លោក ពេជ ម៉ៅល នៅខេត្តកំពង់ធំ*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញគោរពវិញ្ញាណក្ខន្ធវីរជនការពារព្រំដែន លោកព្រឹទ្ធបាលឯក ស៊ឹម គា នៅខេត្តព្រះវិហារ*

ប្រកបដោយព្រហ្មវិហារធម៌ និងជាទីគោរពស្រឡាញ់បំផុត។ ក្រុមភូមិភាគទី៨ បានសម្តែងនូវសមានទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយស្រណោះអាឡោះអាល័យជាទីបំផុត ដែលនេះជាការបាត់បង់នូវកុលបុត្រខ្មែរដ៏អស្ចារ្យនិងធនធានការពារជាតិ ចូលរួមបុព្វហេតុថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ពិសេសការតស៊ូប្រយុទ្ធការពារបូរណភាពទឹកដី ដែនអធិបតេយ្យភាពជាតិ និងការពារប្រជាជនប្រកបដោយភាពអង់អាចក្លាហាន។ ទោះបីរូបកាយបានពលីឃ្លាតចាកពីលោកយើងទៅពិតមែន ប៉ុន្តែវីរយុទ្ធជនបានបង្កើតស្នាដៃសម្រាប់ជាតិ បន្សល់ទុកនូវកេរ្តិ៍ឈ្មោះ និងកិត្តិយសដ៏ឧត្តុង្គឧត្តមដក់ជាប់ក្នុងដួងចិត្តយើងខ្ញុំទាំងអស់គ្នា និងប្រជាជនកម្ពុជាគ្រប់រូបនៅទូទាំងប្រទេស ចងចាំជានិច្ចមិនអាចបំភ្លេចបាន។

ក្រុមភូមិភាគទី៨ បានសម្តែងនូវការគោរពវីរភាពនិងការលះបង់អាយុជីវិតរបស់វីរកងទ័ពកម្ពុជា ពលិកម្មគ្រប់បែបយ៉ាងក្នុងបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ នៅគ្រប់កាលៈទេសៈសំដៅរួមចំណែកយ៉ាងមោះមុត នៅក្នុងការការពារអធិបតេយ្យនិងបូរណភាពទឹកដី ដើម្បីសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជនកម្ពុជា ព្រមទាំងឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធវីរយុទ្ធជនទាំងអស់ បានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញគោរពវិញ្ញាណក្ខន្ធវីរជនការពារព្រំដែន លោកព្រឹទ្ធបាលឯក ឌី សេង នៅខេត្តកំពង់ធំ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាល ជាមួយអាជ្ញាធរស្រុកដំណាក់ចង្អើរ និងក្រុងកែប

នាព្រឹកថ្ងៃសុក្រ ទី២២ ខែសីហា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ (ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប) ដឹកនាំដោយឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មកពីស្រុកដំណាក់ចង្អើរ និងក្រុងកែប ខេត្តកែប សរុបចំនួន ៥៥នាក់។



*ឯកឧត្តម ឈួន ឆាម ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥*

ក្នុងឱកាសនោះ ឯកឧត្តម **ឈួន ឆាម** បានជម្រាបអំពីគោលបំណងនៃពិធីសំណេះសំណាល គឺផ្តោតលើបញ្ហាប្រឈម តម្រូវការ និងសំណូមពរនានារបស់មូលដ្ឋាន ក្នុងការរួមចំណែកលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាននិងការផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាសុខសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យកាន់តែមានភាពប្រសើរឡើង ដោយផ្តោតលើការចុះសួរសុខទុក្ខចំពោះក្រុមគ្រួសារយុទ្ធជនពលី ពិការ ជនភៀសសឹក និងពលករចំណូលស្រុក ដើម្បីប្រមូលព័ត៌មានពីបញ្ហាប្រឈមនិងសំណូមពរក្នុងការប្រកបមុខរបរប្រចាំថ្ងៃ រួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែសម្បូរសប្បាយ។

**ឯកឧត្តមប្រធានស្តីទី** បានលើកទឹកចិត្តចំពោះអាជ្ញាធរ និងប្រជាពលរដ្ឋខេត្តកែប ក្នុងការចុះបំពេញបេសកកម្មយ៉ាងសស្រាក់សស្រាំ ផ្សារភ្ជាប់សុខទុក្ខជាមួយកងទ័ពស្នេហាជាតិ ដែលកំពុងឈរជើងការពារទឹកដី នៅព្រំដែនកម្ពុជា-ថៃ បានល្អរឹងមាំ។ នេះជាការរួមចំណែករបស់អ្នកនៅជួរក្រោយក្នុងការគាំទ្រនិងលើកទឹកចិត្តដល់កងទ័ពជួរមុខ ក៏ដូចជាជួយដល់ប្រជាពលរដ្ឋភៀសសឹកដែលបានចាកចោលផ្ទះសំបែងមករស់នៅទីតាំងបណ្តោះអាសន្នប្រកបដោយសុវត្ថិភាព។

ជាមួយគ្នានេះ **ឯកឧត្តមប្រធានស្តីទី** ក៏បានកោតសរសើរយ៉ាងស្មោះស្ម័គ្របំផុតចំពោះវីរភាពដឹកនាំប្រកបដោយ





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលជាមួយអាជ្ញាធរស្រុកដំណាក់ចង្អើរ និងក្រុងកែប*





*អាជ្ញាធរស្រុកដំណាក់ចង្អើរ និងក្រុងកែប អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល*

មនសិការស្នេហាជាតិដ៏ស្មោះសខ្ពង់ខ្ពស់បំផុតរបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមានភាពប៉ិនប្រសប់ក្នុងការដឹកនាំគ្រប់គ្រងស្ថានការណ៍របស់ប្រទេសជាតិ និងតែងតែស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋគ្រប់កាលៈទេសៈទាំងអស់។

**ឯកឧត្តមប្រធានស្តីទី** បានអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋបន្តរក្សាសាមគ្គីភាព ឯកភាពជាតិ ការពារសន្តិភាព ដែលបានមកដោយលំបាក តាមរយៈការធ្វើពលិកម្មដ៏មហិមារបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា** ដែលជាកត្តាមិនអាចខ្វះបានក្នុងកិច្ចការពារឯករាជ្យភាព អធិបតេយ្យជាតិ បូរណភាពដែនដី វិបុលភាព និងការអភិវឌ្ឍជាតិមាតុភូមិកម្ពុជាឱ្យមានការរីកចម្រើនលើគ្រប់វិស័យ និងបានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខរបស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និងថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនប្រជាពលរដ្ឋក្នុងក្រុង ស្រុក នៃខេត្តកែប និងអង្គពិធីទាំងមូលប្រកបដោយសេចក្តីនឹករលឹកបំផុត។

**ឯកឧត្តមប្រធានស្តីទី** បានគូសបញ្ជាក់ថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់និងបញ្ញាញាណដ៏វាងវៃរបស់ សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នឹងបន្តអនុវត្តលើកស្ទួយនិងជំរុញមុខងារចម្បងទាំង៣របស់ព្រឹទ្ធសភា និងមុខងារគាំទ្រចំនួន២ទៀត ជាពិសេសជំរុញមុខងារតំណាង ដែលជាអាទិភាពចម្បងមួយ ដោយចង្អុលទិសឱ្យសមាជិក សមាជិកាព្រឹទ្ធសភាគ្រប់រូប ធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅទូទាំងប្រទេស ដែលតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន។



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយអាជ្ញាធរ ស្រុកដំណាក់ចង្អើរ និងក្រុងកែប*

**ឯកឧត្តមប្រធានស្តីទី** មានជំនឿយ៉ាងមុតមាំថា ពិធីសំណេះសំណាល ពិតជានឹងផ្តល់នូវគុណតម្លៃបន្ថែមជូនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងស្រុកដំណាក់ចង្អើរ និងក្រុងកែប ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីរួមចំណែកដល់ការជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិឱ្យកាន់តែប្រសើរឡើងជាលំដាប់។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញនាំយកចង្ក្រានសន្សំសំចៃថាមពល ចែកជូនប្រជាពលរដ្ឋក្នុងស្រុកសណ្ដាន់ និងចុះសួរសុខទុក្ខគ្រួសារវីរកងទ័ព

ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាអនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពល និងសារុង ចែកជូនប្រជាពលរដ្ឋចំនួន៥២៣គ្រួសារ នៅវត្តជាន់លែង ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ នាថ្ងៃសុក្រ ទី១៥ ខែសីហា ឆ្នាំ២០២៥។



*លោកជំទាវ មាន សំអាន ប្រធានក្រុមសមាជិកាព្រឹទ្ធសភា*

នាឱកាសនោះ **លោកជំទាវប្រធានក្រុម** បាននាំយកប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខប្រកបដោយក្ដីនឹករលឹកពីសំណាក់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ព្រមទាំងបានជម្រាបជូនបងប្អូនប្រជាពលរដ្ឋទាំងអស់ក្នុងស្រុកសណ្ដាន់ អំពីបញ្ហាជម្លោះប្រដាប់អាវុធទាហានខ្មែរ ជាមួយទាហានថៃ ដែលចាប់ផ្ដើមពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ដោយទាហានថៃបានបាញ់សម្លាប់យុទ្ធជនកម្ពុជាហើយ ចាប់តាំងពីថ្ងៃនោះមកទាហានថៃតែងតែបង្កហេតុគ្រប់បែបយ៉ាងទាំងអស់ រហូតដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ឈានដល់ការផ្ទុះអាវុធ ដោយទាហានថៃជាអ្នកបាញ់ប្រហារមុនមកលើវីរកងទ័ពការពារព្រំដែន និងបានប្រើប្រាស់គ្រាប់បែកចង្កោមយន្តហោះទម្លាក់គ្រាប់បែក ប្រើអាវុធធន់ធ្ងន់ និងប្រើប្រាស់ផ្សែងពុល ដើម្បីធ្វើការឈ្លានពាន និងវាយប្រហារលើវីរកងទ័ព ជនស៊ីវិល និងប្រជាជនស្លូតត្រង់ ដែលកំពុងរស់នៅជាប់ព្រំដែន។

**លោកជំទាវប្រធានក្រុម** បានមានប្រសាសន៍ថា យើងមិនឈ្លានពានទឹកដីគេសូម្បីតែ១តឹក ឬ១ចង្អាមទេ ផ្ទុយទៅវិញយើងត្រូវតែការពារបូរណភាពទឹកដី និងប្រជាជនយើង។ **លោកជំទាវ**បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវតស៊ូ អត់ធ្មត់ រួមសាមគ្គីគ្នា ផ្ដល់ការគាំទ្រ ជឿទុកចិត្តទៅលើសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាធ្លុងមួយឱ្យបានរឹងមាំក្នុងគ្រាដែលប្រទេសជាតិកំពុងជួបប្រទះសង្គ្រាមឈ្លានពានពីថៃ។ ត្រូវឈរជាមួយរាជរដ្ឋាភិបាល រួមមាន





*ក្រុមសមាជិកាព្រឹទ្ធសភា ជួបសំណេះសំណាល និងនាំយកចង្ក្រានសន្សំសំចៃថាមពលជូនប្រជាពលរដ្ឋក្នុងស្រុកសណ្ដាន់ ខេត្តកំពង់ធំ*



*ក្រុមសមាជិកាព្រឹទ្ធសភា ចែកចង្ក្រានសន្សំសំចៃថាមពល ជូនប្រជាពលរដ្ឋក្នុងស្រុកសណ្ដាន់ ខេត្តកំពង់ធំ*

អាជ្ញាធរខេត្ត អាជ្ញាធរស្រុក ភូមិ ឃុំរបស់យើង និងចូលរួមចំណែកជួយឧបត្ថម្ភកងកម្លាំងការពារជួរមុខ តាមរយៈការស្ម័គ្រចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបាន យើងក៏ត្រូវរួមចំណែកដោះស្រាយទប់ស្កាត់ដោយខ្លួនយើង និងជម្នះរាល់ការលំបាកខ្លួនឯងផងដែរ ។

**លោកជំទាវប្រធានក្រុម** បានគូសបញ្ជាក់ថា ការចែកចង្ក្រានសន្សំសំចៃថាមពលជូនបងប្អូន គឺដើម្បីឱ្យយើងទាំងអស់គ្នាចូលរួមសន្សំសំចៃថាមពលនិងការពារបរិស្ថាន ការពារសុខុមាលភាព និងចូលរួមចំណែកក្នុងការកាត់បន្ថយនូវការចំណាយរបស់បងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ អំណោយដែលចែកជូន គឺប្រជាពលរដ្ឋក្នុង១គ្រួសារៗ ទទួលបានចង្ក្រានសន្សំសំចៃថាមពលចំនួន១ និងសារុងចំនួន១ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់អនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ស្រុក និងរដ្ឋបាលស្រុកសណ្ដាន់។





*ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធវីរជនការពារព្រំដែន លោក ពេជ ង៉ោល នៅខេត្តកំពង់ធំ*

បន្ទាប់មកនៅថ្ងៃដដែល **ក្រុមសមាជិកាព្រឹទ្ធសភា** បានអញ្ជើញទៅភូមិរំពុះ ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដើម្បីចូលរួមរំលែកទុក្ខគ្រួសារសពលោក **ពេជ ង៉ោល** វីរយុទ្ធជនការពារព្រំដែន និងអញ្ជើញចុះសួរសុខទុក្ខគ្រួសារវីរយុទ្ធជនចំនួន២គ្រួសារ ក្នុងក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលត្រូវបានទាហានថៃចាប់ខ្លួនក្រោយមានបទឈប់បាញ់ចូលជាធរមាន កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខគ្រួសារវីរយុទ្ធជនចំនួន២គ្រួសារ ក្នុងក្រុងព្រះវិហារ ខេត្តព្រះវិហារ*

# ឯកឧត្តម ម៉ម ប៊ុននាង ទទួលស្វាគមន៍សមាគមនិស្សិតកម្ពុជាប្រចាំប្រទេសចិន មកបំពេញទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភា

ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) បានអញ្ជើញទទួលស្វាគមន៍គណៈប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ចំនួន១០៦នាក់ មកបំពេញទស្សនកិច្ចស្វែងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃចន្ទទី២៨ ខែកក្កដា ឆ្នាំ២០២៥។



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*

នាឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បានធ្វើបទបង្ហាញជូនដល់គណៈប្រតិភូ អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីការចាប់បដិសន្ធិនីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ និងការវិវត្តប្រែប្រួលពីមួយនីតិកាលទៅមួយនីតិកាលទៀត រហូតដល់បច្ចុប្បន្ន គឺព្រឹទ្ធសភា នីតិកាលទី៥។

**ឯកឧត្តម** បានមានប្រសាសន៍ថា ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិក រដ្ឋសភាទាំងមូល។ ក្នុងនីតិកាលទី៥នេះ ព្រឹទ្ធសភាមានសមាជិកចំនួន៦២រូប ក្នុងនោះ ៥៨រូប ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកលពីសំណាក់សមាជិករដ្ឋសភា និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែង, ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប។ អាណត្តិរបស់ព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ។

**ឯកឧត្តម** បានគូសបញ្ជាក់ថា ព្រឹទ្ធសភា នីតិកាលទី៥ ដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រធាន, ឯកឧត្តម **អ៊ុច បូររិទ្ធ** ជាអនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** ជាអនុប្រធានទី២។ ព្រឹទ្ធសភា មានគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាក្បាលម៉ាស៊ីន មានសមត្ថកិច្ចសម្រេចរាល់សកម្មភាពរបស់យន្តការនានានៃព្រឹទ្ធសភា។ ព្រឹទ្ធសភានៅមានយន្តការផ្សេងទៀតដូចជា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨, ក្រុមសមាជិកាព្រឹទ្ធសភា, ក្រុមសមាជិកព្រឹទ្ធសភា, ក្រុមមិត្តភាពទ្វេភាគីជាមួយសភាបណ្ដាលប្រទេសនានាលើសកលលោក និងជាមួយអង្គការអន្តរជាតិ ដូចជា សភាប្រើភាសាបារាំង, សហភាពអន្តរសភា, វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក, សភាតំបន់អាស៊ី





*ឯកឧត្តម ម៉ម ប៊ុននាង ធ្វើបទបង្ហាញអំពីព្រឹទ្ធសភា ជូនប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន*





*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន*

បណ្តាញសភានៃក្រុមប្រទេសចលនាមិនចូលបក្សសម្ព័ន្ធជាដើម។

ព្រឹទ្ធសភា មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យគុណភាពនៃអំណាចរដ្ឋ ដោយធានាថា សេចក្តីសម្រេចនានាត្រូវបានធ្វើឡើងដោយឆ្លុះបញ្ចាំងពីគុណតម្លៃនិងបំណងប្រាថ្នារបស់សង្គមជាតិនិងប្រជាពលរដ្ឋ។

ក្នុងនាមជាចំណែកមួយនៃអង្គនីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានមុខងារចំនួន៣ គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ នៅនីតិកាលទី៥នេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប៊ិនប្រសប់ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** បានកំណត់អាទិភាពចម្បង២ គឺការរួមប្រាស្រ័យឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត និងការងារលើកកម្ពស់ការទូតសភា។

ឯកឧត្តម **ម៉ម ប៊ុននាង** បានអំពាវនាវដល់និស្សិតទាំងអស់ឱ្យមានការអត់ធ្មត់ ហើយជឿទុកចិត្តលើការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដែលមាន**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខដឹកនាំ ប្រទេសជាតិយើងនឹងទទួលបាននូវសុខសន្តិភាព និងប្រក្រតីភាពឡើងវិញ ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ពីការឈ្លានពានរបស់កងទ័ពថៃ។

ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ ឧុទ្ធទី** ស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលសមាគមនិស្សិតកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន បាននាំថវិកាចំនួន ១៦លានរៀល ដែលទទួលបានពីការចូលរួមមនុស្សធម៌របស់សមាជិកសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ប្រគល់ជូនឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការដែលបានចូលរួមចំណែកឧបត្ថម្ភជូនដល់កងទ័ពជួរមុខកម្ពុជា នៅតាមព្រំដែនកម្ពុជា-ថៃ។

បន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញរួចមក គណៈប្រតិភូបានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានានៅក្នុងបរិវេណវិមានព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន អញ្ជើញទស្សនាអគារ និងសាលប្រជុំព្រឹទ្ធសភា*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមតួមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

**❈គណៈកម្មការទី១ព្រឹទ្ធសភា ជួបភ្ញៀវជាតិ ចំនួន២លើក៖**



ឯកឧត្តម **ឪ ច័ន្ទផល** ប្រធានគណៈកម្មការ បាន៖

-ទទួលជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាសកម្មភាពជនពិការ(ក.ស.ជ) ដឹកនាំដោយឯកឧត្តម **ម៉េត មករា** អនុប្រធាន ក.ស.ជ និងជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្វែងយល់អំពីវឌ្ឍនភាពការងារទាក់ទងនឹងការលើកម្ពស់សិទ្ធិជនពិការ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥។



-ទទួលជួបជាមួយប្រជាពលរដ្ឋជាម្ចាស់បណ្ដឹងឈ្មោះ **មឿន ជុំ** មកពីភូមិស្រែក្រសាំង ឃុំស្រែក្រសាំង ស្រុកសៀមបូក ខេត្តស្ទឹងត្រែង អញ្ជើញមកថ្លែងអំណរគុណចំពោះសម្តេចតេជោប្រធានព្រឹទ្ធសភា ដែលបានជួយអន្តរាគមន៍ទៅឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ដោះស្រាយបណ្ដឹងរបស់គាត់ទទួលបានជោគជ័យ ដោយរូបគាត់នឹងទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនាពេលខាងមុខ នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន២លើក៖**

ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី២៥ ខែកក្កដា



ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-ការបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែកក្កដា ឆ្នាំ២០២៥

២-ការបូកសរុបរបាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែកក្កដា ឆ្នាំ២០២៥

៣-បញ្ហាផ្សេងៗ។



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើការងារសំខាន់ៗរបស់គណៈកម្មការ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន៣លើក៖**



លោកជំទាវ **ចាន់ សុខុនាវី** ប្រធានគណៈកម្មការ បាន

ដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥ ពិភាក្សាអំពី៖

១-ការចុះបំពេញបេសកកម្មរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា ចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥

២-បញ្ហាផ្សេងៗ

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នារសៀលថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ ដើម្បីណែនាំដល់មន្ត្រីការិយាល័យជំនួយការគណៈកម្មការ រៀបចំរបាយការណ៍វឌ្ឍនភាពនៃការសិក្សារៀបចំ សេចក្តីស្នើច្បាប់ស្តីពី «វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា» និងសេចក្តីថ្លែងហេតុអំពីសេចក្តីស្នើច្បាប់ស្តីពី «វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា»។

-នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការ បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិភាក្សាអំពីការចុះបំពេញបេសកកម្មរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា ចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ ទៅខេត្តបន្ទាយមានជ័យ និងបញ្ហាផ្សេងៗ។

**❖កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន១លើក៖**



នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖១-របាយការណ៍ ស្តីពីលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២៥ ២-បញ្ហាផ្សេងៗ។

**❖កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន២លើក៖**

លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាអំពីការសម្រេចចុះបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ និងបញ្ហាផ្សេងៗ។



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើការបូកសរុបលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែសីហា ឆ្នាំ២០២៥ និងទិសដៅខែកញ្ញា ឆ្នាំ២០២៥ ព្រមទាំងបញ្ហាផ្សេងៗ។

**❖កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចំនួន១លើក៖**

នារសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុម ដើម្បីពិភាក្សាអំពីគម្រោងរៀបចំវេទិកានៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងបញ្ហាផ្សេងៗ។

**❖កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន១លើក៖**



នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ពិភាក្សាលើវឌ្ឍនភាពការងាររបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ និងបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក៖**

នារសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែសីហា របស់គណៈកម្មការ និងលើកទិសដៅការងារបន្ត។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចំនួន២លើក៖**

ឯកឧត្តម **ឈួន ឆាម** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងក្រុម នាព្រឹកថ្ងៃអង្គារទី២៩ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពប្រចាំខែកក្កដា និងលើកទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២៥

២-របាយការណ៍លទ្ធផលនៃពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៃស្រុកគិរីវង់ និងស្រុកទ្រាំង ខេត្តតាកែវ

៣-បញ្ហាផ្សេងៗ។





-កិច្ចប្រជុំផ្ទៃក្នុងក្រុម នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើគម្រោងចុះបេសកកម្មជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅខេត្តកែបនាពេលខាងមុខ និងបញ្ហាផ្សេងៗ៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែសីហា ឆ្នាំ២០២៤ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៣បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែនចំនួន១បណ្តឹង បានទទួលលិខិតថ្លែងអំណរគុណពីម្ចាស់បណ្តឹងគោរពជូន**សម្តេចតេជោប្រធានព្រឹទ្ធសភា**តាមរយៈគណៈកម្មការចំនួន១បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សាចំនួន៥បណ្តឹង តម្កល់ទុកមិនចាត់ការចំនួន១បណ្តឹង បានទទួលលិខិតឆ្លើយតបចំនួន៥បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន**សម្តេចតេជោប្រធានព្រឹទ្ធសភា**អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៥បណ្តឹង រំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន២បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងចំនួន៦បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន២បណ្តឹង៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារ នៅតាមបណ្តាភូមិភាគទាំង៨

❈នាព្រឹកថ្ងៃអង្គារ ទី២៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និង លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលនិងដឹកនាំក្រុម គ្រូពេទ្យស្ម័គ្រចិត្តរបស់អង្គការសង្គ្រោះវេជ្ជសាស្ត្រអន្តរជាតិ ប្រចាំនៅកម្ពុជា (IMR) ចុះមកពិនិត្យនិងព្យាបាលជំងឺដោយ ឥតគិតថ្លៃជូនប្រជាពលរដ្ឋចំនួន១ថ្ងៃ នៅក្នុងបរិវេណវត្ត ជម្លង់ម្លូ សង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល រាជធានីភ្នំពេញ។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចុះពិនិត្យ និងដឹកនាំក្រុមការងាររៀបចំសម្ភារៈ ស្បៀង អាហារដូចជា៖ គ្រឿងឧបភោគ បរិភោគ ទឹកបរិសុទ្ធ មីកញ្ចប់ ផ្លែឈើ ថ្នាំសង្កូវ និងសម្ភារៈប្រើប្រាស់ជាច្រើនផ្សេងៗទៀត ដើម្បីដឹកជញ្ជូនយកទៅចែកជូនប្រជាជនភៀសសឹក នៅ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ នៅខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខបុគ្គលិកជាស្ត្រី នៅក្នុងសិប្បកម្មផលិតសាប៊ូខ្មែរ នៅក្រុងសៀមរាប ខេត្ត សៀមរាប នារសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករកំពុងប្រមូល ផលផ្លែត្របែក ព្រមទាំងបានណែនាំពួកគាត់ពីរបៀបផ្សាំផ្លែ ត្របែកបន្ថែមទៀត នៅភូមិស្វាយជង្គុំ ស្រុកសំពោងទង ខេត្ត កំពង់ស្ពឺ នារសៀលថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។

-ទទួលដំណើរទស្សនកិច្ចរបស់លោកគ្រូ អ្នកគ្រូ សិស្សា-នុសិស្ស កុមារា និងកុមារី ដែលមកទស្សនកិច្ចសិក្សាក្នុង គោលបំណងផ្តល់ឱកាសដល់សិស្សានុសិស្ស បានក្រេប ជញ្ជក់ចំណេះដឹងជាក់ស្តែងក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍ កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភូមិមហាលំពាំង ទី២ ឃុំសែនជ័យ ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ នារសៀល ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥។

-ទទួលជួបជាមួយក្រុមអ្នកវិនិយោគទុនជនជាតិជប៉ុន ដែលដឹកនាំដោយលោក TERUYUKI FUKUDA Director KISCO LTD និងលោក NAOKI SAKAI Managing Director KISCO(Cambodia) Co.,LTD មានគោលបំណង ចង់វិនិយោគទុនលើ វិស័យកសិកម្មឱ្យកាន់តែលូតលាស់ និង ជំរុញការកែច្នៃផលិតផលកសិផល ដើម្បីនាំចូលទៅកាន់ទីផ្សារ ក្រៅប្រទេស នៅភូមិសែនជ័យ ឃុំសែនដី ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះ ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្លូវឡូរី ដើម្បីតាមដានលើវឌ្ឍនភាព ផ្លូវ និងពិនិត្យលើបច្ចេកទេស ស្ថានភាពផ្លូវ និងបញ្ហាប្រឈម ព្រមទាំងបាននាំយកនំខ្មែរចែកជូនកម្មករ នៅភូមិស្វាយជង្គុំ ឃុំសែនដី ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃចន្ទ ទី៧ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បាន អញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ បងប្អូនប្រជាពលរដ្ឋ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ព្រមទាំងបានឧបត្ថម្ភ សម្ភារៈ និងថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋ នៅសង្កាត់ជ្រោយតាកែវ ក្រុងសំពៅពូន ខេត្តកណ្ដាល។



❈នារសៀលថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា និងសម្តេច រាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈ-

កម្មការទី១០ព្រឹទ្ធសភា បានយាង/អញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោក **សំរិត ទ្រី** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន ព្រមទាំងបានចូលបច្ច័យបុណ្យមួយចំនួន នៅភូមិកគោ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-គោរពវិញ្ញាណក្ខន្ធ និងដង្ហែសពវកិលដាក់មេរុ លោកអនុសេនីយ៍ត្រី **មឿន សារ៉េត** ជាយោធិនកងពលធំអន្តរាគមន៍លេខ២ កងទ័ពជើងគោក ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពានដើម្បីការពារបូរណភាពទឹកដី នៅវត្តកស្សបៈ នៅភូមិដងទង ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នារសៀលថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥។

-ទស្សនកិច្ចនៅអាកាសយានដ្ឋានថ្មីមរតកតេជោ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-គោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ទោ **តែម សុខជា** ជាយោធិនបម្រើការងារនៅកងឯកភាព កងពលធំអន្តរាគមន៍លេខ៣ ជ.គ. ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន ព្រមទាំងបាននាំបច្ច័យមួយចំនួនចូលរួមក្នុងពិធីបុណ្យ នៅភូមិទួលស្តី ឃុំទួលស្តី ស្រុកចន្ទ្រា ខេត្តស្វាយរៀងនាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមពិធីបុណ្យឆ្លងព្រះវិហារ និងសមិទ្ធផលនានាក្នុងវត្តទួលអង្គញ់ និងពិធីប្រគេនទៀនចំណាំព្រះវស្សាដល់ព្រះសង្ឃចំនួន៩វត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេច



កិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តទួលអង្គញ់ ភូមិទួលអង្គញ់ ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២៥។



-ចូលរួមពិធីបុណ្យ និងសួរសុខទុក្ខដល់ក្រុមគ្រួសារសព លោកអនុសេនីយ៍ឯក **ញឹក ប៊ុនសោន** ជាយោធា បម្រើការងារនៅកងពលតូចអន្តរាគមន៍លេខ៤៨ ប្រចាំការនៅសមរភូមិជួរមុខតំបន់ភ្នំទ្រព្យ បានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិតាប៉ោ ឃុំសំឡី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខគ្រួសារយុទ្ធជនក្នុងខេត្តស្វាយរៀង ដែលថៃបានចាប់ជាចំណាប់ខ្មាំងកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ នារសៀលថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥។



❋នាថ្ងៃពុធ ទី៣០ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បាន អញ្ជើញដឹកនាំគណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិ ភាគទី៣ ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារនៃសព និង គោរពវិញ្ញាណក្ខន្ធសព លោកអនុសេនីយ៍ត្រី **រិន វាសនា វីរៈ** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិ ជាមួយសៀមឈ្លានពាននិងបានចូលបច្ច័យបុណ្យមួយចំនួន នៅស្រុកអង្គស្នួល ខេត្តកណ្ដាល។

❋ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូក្រុមសមាជិក ព្រឹទ្ធសភាប្រចាំភូមិភាគទី៥៖

-គោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ត្រី **ស្ងួន ពេជ្រ**



ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយ សៀមឈ្លានពាន នៅសមរភូមិភ្នំទ្រព្យ ខេត្តព្រះវិហារ ដើម្បី ការពារបូរណភាពទឹកដីកម្ពុជា ព្រមទាំងនាំយកថវិកាក្រុម សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចូលរួមថវិកាជាមួយ គ្រួសារសពមួយចំនួន នៅភូមិជ័រជុំ ឃុំកាំងស្បូវ ស្រុកឈូក ខេត្តកំពត នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។



-គោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ត្រី **ចាន់ វឌ្ឍនា** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយ សៀមឈ្លានពាន នៅសមរភូមិភ្នំទ្រព្យ ខេត្តព្រះវិហារ ដើម្បី ការពារបូរណភាពទឹកដីកម្ពុជា នៅភូមិអំពែង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ ២០២៥។



-គោរពវិញ្ញាណក្ខន្ធសពលោកពលបាលឯក **ឈួក វ៉ាន់ត្រួយ** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើ សមរភូមិជាមួយសៀមឈ្លានពាន នៅសមរភូមិភ្នំទ្រព្យ ខេត្ត ព្រះវិហារ ដើម្បីការពារបូរណភាពទឹកដីកម្ពុជា នៅឃុំចំប៉ី ស្រុកអង្គជ័យ ខេត្តកំពត នារសៀលថ្ងៃទី១ ខែសីហា ឆ្នាំ ២០២៥។



-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចុះពិនិត្យវឌ្ឍនភាព នៃការជីកស្តារស្រះទឹកទន្លេនាម នៅឃុំអង្គចំប៉ី ស្រុកអង្គជ័យ ខេត្តកំពត នារសៀលថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

❋ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំបូកសរុបរបាយការណ៍ពី សភាពការណ៍ ទូទៅ និងលទ្ធផលការងារឆមាសទី១ និងទិសដៅភារកិច្ច ឆមាសទី២ ឆ្នាំ២០២៥ ក្រោមអធិបតីភាពលោកជំទាវ **មិថុនា ភូថង** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមធ្វើបទឧទ្ទេសនាម ស្តីពី «សភាពការណ៍កម្ពុជា

និងបណ្ដាភាកិច្ចចំពោះមុខ» ក្នុងវគ្គអប់រំនយោបាយ នៅខេត្តកោះកុង នាថ្ងៃទី២៦ និងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥។



❈នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំជាមួយមេភូមិទាំង១៣ និងក្រុមប្រឹក្សាសង្កាត់ ដើម្បីស្ដាប់របាយការណ៍ ស្ដីពីលទ្ធផលការងារខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២៥ បន្តពង្រឹងការពារសុខសុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ ការងារសប្បុរសធម៌ជួយផ្គត់ផ្គង់ជនភៀសសឹកតាមបណ្ដោយបន្ទាត់ព្រំដែន ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនសម្រាប់ថៃទាំការពារសុខភាពមនុស្សចាស់ប្រចាំខែសីហា ឆ្នាំ២០២៥ នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

❈នាថ្ងៃចន្ទ ទី១៤ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក និងបានឧបត្ថម្ភថវិកាមួយចំនួនជូន៩គ្រួសារ ក្នុងឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❈ឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ឯក **អ៊ុន វណ្ណា** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន និងបានចូលបច្ច័យបុណ្យមួយចំនួន នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមឧបត្ថម្ភថវិកាមួយចំនួនតាមការអំពាវនាវរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីលើកស្ទួយបុព្វហេតុការពារជាតិមាតុភូមិ ជាពិសេសដល់វីរយុទ្ធជន និងជនភៀសសឹក នៅតាមបណ្ដាខេត្តនានាតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ នាថ្ងៃ៥ ខែសីហា ឆ្នាំ២០២៥។

❈នារសៀលថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខភរិយាកងទ័ពជួរមុខ លោកពលទោ **សុខ រដ្ឋា** ដែលកំពុងមានផ្ទៃពោះជិតសម្រាល និងបានឧបត្ថម្ភថវិកាមួយចំនួន នៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

❈នាព្រឹកថ្ងៃពុធ ទី១៦ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងលើកទិសដៅការងារបន្ត ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅឃុំក្រពុំឈូក ស្រុកកោះអណ្ដែត ខេត្តតាកែវ។

❈នាព្រឹកថ្ងៃអង្គារ ទី៨ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ និងស្មៀន និងនាយប៉ុស្ដិ៍ ក្នុងឃុំកោពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមក្នុងពិធីដាំដើមឈើជាមួយប្រជាពលរដ្ឋ ក្រោមប្រធានបទ «ពន្លកបៃតង ដើម្បីសោភ័ណភាពបរិស្ថាននៅក្នុងសហគមន៍យើង» និងបានចែកកូនឈើក្ងោក ចំនួន៥០០ដើម ដល់ប្រជាជនចំនួន៧ភូមិ ដើម្បីដាំតាមដងផ្លូវ ក្នុងភូមិ នារដូវវស្សានេះ នៅឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥។



-អមសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាសព លោកអនុសេនីយ៍ទោ **តែម សុខជា** ជាយោធិនបម្រើការងារនៅកងឯកភាពលេខ៤៨ ចំណុះឱ្យកងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក នៃកងយុទ្ធពលខេមរភូមិន្ទ បានពលីជីវិតនៅលើសមរភូមិប្រយុទ្ធខេត្តព្រះវិហារ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ៤៣ឆ្នាំ ព្រមទាំងបាននាំបច្ច័យមួយចំនួនរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចូលរួមក្នុងពិធីបុណ្យ នៅភូមិទួលស្ដី ឃុំទួលស្ដី ស្រុកចន្ទ្រា ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមដង្ហែក្បួនថ្មើរជើង «កម្ពុជាស្រឡាញ់សន្តិភាព




(CAMBODIA LOVES PEACE)» នៅរង្វង់មូលវិមានឯករាជ្យ ខេត្តស្វាយរៀង នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត ចុះជួបក្រុមការងារប្រចាំការរបស់គណៈកម្មការសម្រាប់ត្រៀមនូវសភាពការណ៍សន្តិសុខព្រំដែននិងសន្តិសុខសណ្ដាប់ធ្នាប់ផ្ទៃក្នុង ស្ថិតក្នុងភូមិសាស្រ្ត ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលបានចាកចេញពីលំនៅដ្ឋានតាមបណ្ដោយព្រំដែន ចំនួន៥ភូមិ ស្មើនឹង២១៨គ្រួសារ ក្នុងឃុំស្វាយចេក និងឃុំស្លក្រាម



ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងវត្តសម្បូរណ៍សាមគ្គីប្រាសាទមានជ័យ ភូមិប្រាសាទ ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣៧ អាណត្តិទី៥ របស់ក្រុមប្រឹក្សាឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាអនុម័តលើ៖

១-សេចក្តីព្រាង របៀបវារៈប្រជុំសាមញ្ញលើកទី៣៧

២-ពិនិត្យពិភាក្សាអនុម័តលើសេចក្តីព្រាងកំណត់ហេតុលើកទី៣៦

៣-ពិនិត្យនិងពិភាក្សាអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំខែកក្កដា

៤-ការប្រើប្រាស់ប័ណ្ណសមធម៌

៥-បញ្ហាផ្សេងៗ។



-ចុះសួរសុខទុក្ខ និងចែកអំណោយជូនដល់ប្រជាពលរដ្ឋ

ភៀសសឹក ចំនួន៤០០គ្រួសារ មកពីស្រុកបន្ទាយអំពិល និងស្រុកថ្មពួក ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅវត្តស្នើសាមគ្គីស្ពៅ ភូមិស្ពៅ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមទទួលអំណោយជាគ្រឿងឧបភោគ បរិភោគពីសប្បុរសជន សម្រាប់ជូនដល់កងកម្លាំងអគ្គបញ្ជាការកងរាជអាវុធហត្ថ ប្រចាំភូមិភាគទី៥ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខ និងចែកអំណោយជូនដល់ប្រជាពលរដ្ឋភៀសសឹក នៅទីទួលសុវត្ថិភាពចំនួន២ទីតាំង៖១-ចំនួន១៨៧គ្រួសារ ស្ថិតក្នុងបរិវេណវត្តសម្បូរណ៍សាមគ្គីប្រាសាទមានជ័យ ស្រុកស្វាយចេក និងទីតាំងទីពីរ ចំនួន២៥៨គ្រួសារ ស្ថិតនៅអគារធំឯកជនភូមិ១ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋភៀសសឹក ចំនួន៦០០គ្រួសារ ស្ថិតនៅផ្សារបូរីជ័យចំការតាដោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ព្រមទាំងបន្តចុះជួបប្រជាពលរដ្ឋដែលបានរួមគ្នាវេចនំអន្សមសន្តិភាព ជូនដល់វីរកងទ័ពជួរមុខ និងជនភៀសសឹក ស្ថិតនៅវត្តលំជ្រៃ ឃុំភូមិថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមពិធីដង្ហែក្បួនកាន់ទុក្ខ និងពិធីបង្សុកូលឧទ្ទិសជូនដល់វីរកងទ័ពជួរមុខ ដែលបានបូជាសាច់ស្រស់ ឈាមស្រស់ ពលីជីវិតក្នុងសមរភូមិ ដើម្បីការពារបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា នៅវេទិកាខេត្តបន្ទាយមានជ័យ ព្រមទាំងចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋភៀសសឹក ចំនួន៧០០គ្រួសារ ស្ថិតនៅ២ទីតាំង៖១- បរិវេណវត្តតាប៉ុន ឃុំទឹកជោរ និងទីតាំងទីពីរ សាលាឃុំបុស្បូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋចំនួន៦០០គ្រួសារ ដែលជួបការលំបាកដោយសារសង្គ្រាមតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ស្ថិតនៅទីតាំងវិទ្យាល័យហ៊ុន សែន ម៉ាឡៃ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

-ចូលរួមរំលែកមរណទុក្ខសពលោកស្រី **ផុន លីមបុប្ផល** ដែលបានទទួលមរណភាពក្នុងជន្មាយុ៤១ឆ្នាំ ដោយរោគាពាធ ត្រូវជាភរិយារបស់លោក **នួន ស៊ីណា** ប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តបន្ទាយមានជ័យ ស្ថិតនៅ



គេហដ្ឋានសព ភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥។



-ចូលរួមរំលែកមរណទុក្ខជាមួយលោកស្រី **ជា គីមឡេង** ត្រូវជាភរិយាសពវេជ្ជបណ្ឌិត **ម៉ូ វិចោន** អនុប្រធានមន្ទីរពេទ្យបង្អែកក្រុងសិរីសោភ័ណ ដែលបានទទួលមរណភាព ក្នុងជន្មាយុ៤៩ឆ្នាំ ដោយរោគាពាធ ស្ថិតនៅគេហដ្ឋានសព ភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥។

❈លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកម្មវិធីប្រគេនទៀនចំណាំព្រះវស្សា ដល់ព្រះចៅ



អធិការវត្តចំនួន១២ ក្នុងស្រុកកំពង់ស្វាយ ស្ថិតនៅភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមកម្មវិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋមកពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃ ដោយសមាគមគ្រូពេទ្យស្ម័គ្រចិត្តខេត្តយ៉ុងសាងប៊ុកដូ នៃសាធារណរដ្ឋកូរ៉េ



ស្ថិតនៅមន្ទីរពេទ្យបង្អែក ខេត្តកំពង់ធំ នារសៀលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥។

-គោរពវិញ្ញាណក្ខន្ធនិងរំលែកមរណទុក្ខជាមួយក្រុមគ្រួសារសពលោក **ធី សាំ** អតីតយុទ្ធជនដែលបានជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍បាត់បង់ជីវិត ក្នុងជន្មាយុ៥៥ឆ្នាំ នៅលំនៅដ្ឋានគ្រួសារនៃសព ស្ថិតនៅភូមិមាំងងាប់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខវីរកងទ័ពចំនួន៣នាក់ ដែលបានរងរបួសកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។



❈នាព្រឹកថ្ងៃអង្គារ ទី៨ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជាគណៈអធិបតីក្នុងកម្មវិធីចែកអំណោយដល់ជនភៀសសឹកមកពីខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ សរុបចំនួន២,៥៦៥គ្រួសារ ក្រោម

អធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ស្ថិតនៅ ពហុកីឡដ្ឋានខេត្តកំពង់ធំ ភូមិរូង ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។



❈នាល្ងាចថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ចឹក ហោខ** សមាជិកាគណៈកម្មការទី៤ ព្រឹទ្ធសភា បានអញ្ជើញចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពវីរកងទ័ពកម្ពុជា លោកព្រឹន្ទបាលឯក **ឌី សេខ** អនុសេនាធំលេខ៣ វរសេនាតូច៣៨២ ខេត្តព្រះវិហារ ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសង្គ្រាមឈ្លានពានរបស់សៀម ដើម្បីការពារបូរណភាពទឹកដីកម្ពុជា ស្ថិតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីបុណ្យទក្ខិណានុប្បទានខួបគម្រប់៧ថ្ងៃ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលឯក **ឆៃ វ័ន្ធ** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន និងបានចូលបច្ច័យបុណ្យមួយចំនួន នៅឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នៅព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

-ចូលរួមពិធីបុណ្យទក្ខិណានុប្បទានខួបគម្រប់៧ថ្ងៃ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ឯក **អ៊ុន ចន្ថា** ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន និងបានចូលបច្ច័យបុណ្យមួយចំនួន នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុក



ទឹកឈូ និងនៅភូមិតាដិប សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត នាថ្ងៃទី២៥ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមក្នុងពិធីរៀបចំទទួលសម្ភារៈដែលបងប្អូនសប្បុរសជនយកមកផ្ញើសម្រាប់ជូនវីរកងទ័ពដែលបានការពារទឹកដី និងប្រជាពលរដ្ឋភៀសខ្លួន នៅក្នុងភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមជាអធិបតីក្នុងពិធីប្រគល់និងទទួលសម្ភារៈ រួមមាន៖ មីចំនួន៤៧កេស ទឹកបរិសុទ្ធចំនួន៤៤យួរ ព្រមទាំងថវិកាមួយចំនួនដែលជាអំណោយរបស់សប្បុរសជន (ប្រជាពលរដ្ឋ) ដែលរស់នៅក្នុងភូមិត្រពាំងសង្កែ (ក្បាលរមាស) ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត ដើម្បីជួយឧបត្ថម្ភគាំទ្រដល់វីរកងទ័ព និងប្រជាពលរដ្ឋភៀសសឹក ដោយមានការចូលរួមពីសំណាក់លោកអភិបាលរងស្រុកទឹកឈូ និងក្រុមការងារជាក្រុមប្រឹក្សាឃុំ ក្រុមការងារថ្នាក់ដឹកនាំវិហារគ្រូបង្រៀន និងប្រជាពលរដ្ឋ នាល្ងាចថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

-ជូនដំណើរបងប្អូនសាសនិកអ៊ីស្លាម ដែលត្រូវចេញដំណើរទៅបំពេញបេសកកម្មហាជ្ជី (ធម្មយាត្រាហាជ្ជីអុំរ៉ស់) នៅ





ប្រទេសអារ៉ាប៊ីសាអូឌីត រយៈពេល១៥ថ្ងៃ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នារសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥។



-ជួបពិភាក្សាការងារជាមួយលោកស្រីមេឃុំត្រពាំងសង្កែ និងមន្ត្រីឃុំ នៅស្រុកទឹកឈូ ខេត្តកំពត និងបានចូលរួមពិសាអាហារសាមគ្គីជាមួយថ្នាក់ដឹកនាំខ្មែរអ៊ីស្លាម និងបងប្អូនប្រជាពលរដ្ឋ នាល្ងាចថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។



-ចូលរួមពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធ ឯកឧត្តម **ទេព យុទ្ធី** អតីតសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដែលប្រារព្ធនៅភូមិដំណាក់ចំបក់ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប នាល្ងាចថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក និងប្រជាពលរដ្ឋខ្មែរអ៊ីស្លាម នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត ក្នុងពិធីទទួលថវិកាសម្រាប់ផ្ដល់ជូនវីរកងទ័ព និងជនភៀសសឹកតាមរយៈក្រុមការងារស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥។

❈ឯកឧត្តម **គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖

-គោរពវិញ្ញាណក្ខន្ធ លោកព្រឹទ្ធបាលឯក **ហេង តាំង** និងលោកវរសេនីយ៍ត្រី **អ៊ួន ហាច** វីរកងទ័ពបានពលីក្នុងការការពារបូរណភាពទឹកដី ស្ថិតនៅឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខ និងយកគ្រឿងឧបភោគ បរិភោគមួយចំនួនជួយបងប្អូនប្រជាពលរដ្ឋភៀសសឹកដែលរងគ្រោះដោយការឈ្លានពានពីកងទ័ពថៃ ស្ថិតនៅវត្តប្រមោយ ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នារសៀលថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខ និងយកគ្រឿងឧបភោគ បរិភោគមួយចំនួនជួយបងប្អូនប្រជាពលរដ្ឋភៀសសឹកដែលរងគ្រោះដោយការឈ្លានពានពីកងទ័ពថៃ ស្ថិតនៅវត្តបន្ទាយស្រី ស្រុកបន្ទាយស្រី និងវត្តសុវណ្ណបទម ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ ស្ថិតនៅឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ ស្ថិតនៅស្រុកកញ្ជៀច ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ ស្ថិតនៅសង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នារសៀលថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែ និងលើកទិសដៅការងារបន្តរបស់រដ្ឋបាលស្រុកជើងព្រៃ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកចូលរួម នៅខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខ និងនាំយកនូវសម្ភារៈ ព្រមទាំងថវិកាមួយចំនួន ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងថវិកាផ្ទាល់របស់លោកជំទាវបណ្ឌិត ជូនជនភៀសសឹកចំនួន ១៤គ្រួសារ មកពីខេត្តព្រះវិហារ បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ នៅសាលាស្រុកជើងព្រៃ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥។

-ជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធិផលនានា ក្នុងវិទ្យាល័យហ៊ុនសែន ជើងធ្នុក និងសាលាបឋមសិក្សាជើងធ្នុក ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនប្រជាជន កងកម្លាំង សេនាជន និងសិស្សានុសិស្ស ចំនួន៧០០នាក់ នៅភូមិជើងធ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃពុធ ទី១៦ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ញ៉ូច សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាមួយរដ្ឋបាលខេត្តពោធិ៍សាត់ និងមន្ទីរអង្គភាពជុំវិញខេត្ត ដឹកនាំដោយឯកឧត្តម **ម៉ក់ រ៉ា** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ខូយ រីដា** អភិបាល នៃគណៈ-អភិបាលខេត្ត ដើម្បីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ខូយ គឹមឆ្ន** ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលបានទទួលមរណភាពដោយរោគាពាធក្នុងជន្មាយុ៨១ឆ្នាំ នៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

❈នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **សត ណាឌី**



សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញនាំយកសម្ភារៈ និងគ្រឿងបរិភោគជូនដល់ប្រជាពលរដ្ឋ ដែលបានភៀសសឹកពីភូមិកូនក្រៀល ខេត្តឧត្តរមានជ័យ មកស្នាក់នៅក្នុងឃុំគោល ស្រុកអង្គរជុំ ចំនួន៣០គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបាន អង្ករ២០គីឡូក្រាម, មី១កេស, ទឹកត្រី ទឹកស៊ីអ៊ីវ, ត្រីខ, ទឹកបរិសុទ្ធ និងថវិកាមួយចំនួន នៅឃុំគោល ស្រុកអង្គរជុំ ខេត្តសៀមរាប។

❈ឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីប្រារព្ធធ្វើបទនមស្ការ សមាទានសីល និមន្ត



ព្រះសង្ឃចម្រើនព្រះបរិត្ត និងនិមន្តព្រះធម្មកថិក២ព្រះអង្គសំដែងធម៌ទេសនា ក្នុងពិធីបុណ្យទក្ខិណានុប្បទានប្រគេនព្រះឥន្ទមុនី **អ៊ុក មុត** ព្រះរាជាគណៈថ្នាក់ចត្វា ព្រះសង្ឃកិច្ចកោសល ព្រះមេគុណខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនិងលោកជំទាវ ពិធីប្រារព្ធធ្វើនៅក្នុងបរិវេណវត្តពោធិ៍វាល នៅសង្កាត់រតនៈ ក្រុងបាត់ដំបង នារសៀលថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប៧ថ្ងៃ ប្រគេនព្រះវិញ្ញាណក្ខន្ធ ព្រះឥន្ទមុនី **អ៊ុក មុត** ព្រះរាជា-គណៈថ្នាក់ចត្វា ព្រះសង្ឃកិច្ចកោសល ព្រះមេគុណខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សា ផ្ទាល់ព្រះមហាក្សត្រ និងលោកជំទាវ ពិធីប្រារព្ធធ្វើនៅក្នុងបរិវេណវត្តពោធិ៍វាល នៅសង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥។

-អមដំណើរសម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចុះត្រួតពិនិត្យស្ថានភាពច្រកទ្វារព្រំដែនអន្តរជាតិដូង ស្រុកកំរៀង



ខេត្តបាត់ដំបង ដើម្បីទទួលស្វាគមន៍បងប្អូនពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ និងលើកទឹកចិត្តដល់មន្ត្រីរាជការដែលកំពុងប្រចាំការសម្របសម្រួលក្នុងការវិលត្រឡប់របស់ពលករ និងជួយសម្រួលឱ្យបងប្អូនពលករយើងបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញដោយសុវត្ថិភាព នារសៀលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥។

-គោរពវិញ្ញាណក្ខន្ធលោកនាយចំណង់ **ទេព ម៉ានុន** ជាយុទ្ធជនទ័ពពិសេសផ្ទៃឃោង កងពល៥១១ ដែលបានពលីជីវិតលើសមរភូមិ នៅថ្ងៃសៅរ៍ទី២៦ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ៣២ឆ្នាំ និងលោកនាយចំណង់ **ឈឿន ចាន់ណា** ជាយុទ្ធជនកងពលតូចលេខ៨ នៃវរសេនាតូច៣៨២ ដែលបានពលីជីវិតលើសមរភូមិភ្នំទ្រព្យ នៅថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ៥៥ឆ្នាំ នៅលំនៅដ្ឋានគ្រួសារនៃសព ស្ថិតក្នុងឃុំខ្នាចរមាស ស្រុកបវេល និងឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ ២០២៥។



-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១០ ក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងបរិវេណចំណុចគីឡូលេខ២០៧ (ច្រកចង្អៀត) ស្ថិតនៅភូមិព្រៃធំ ឃុំកំពង់ល្ពៅ ស្រុកសំឡូត ខេត្តបាត់ដំបង នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥។

❈លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យខួបគម្រប់៧ថ្ងៃ លោក **ជា សារុន** សមាជិកក្រុមប្រឹក្សាសង្កាត់ផ្សារដើមថ្កូវ ដែលបានទទួលមរណភាពក្នុងជន្មាយុ៦៦ឆ្នាំ ដោយរោគាពាធ ព្រមទាំងនាំយកបច្ច័យមួយចំនួនជូនដល់ក្រុមគ្រួសារសព ស្ថិតនៅគេហដ្ឋាន ផ្ទះលេខ៣៨អ៊ី ផ្លូវ៥១បេតេ ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃអង្គការសង្គ្រោះវេជ្ជសាស្ត្រអន្តរជាតិប្រចាំនៅកម្ពុជា (IMR) និងសមាជិកក្រុមប្រឹក្សាសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ នៅវត្តឥន្ទពិសី សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥។



-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋមកពីភូមិទាំង៥ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន ស្ថិតក្នុងសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលជាមួយពលករត្រឡប់មកពីប្រទេសថៃ ចំនួន៩២គ្រួសារ នៅស្រុកបរិបូណ៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាមន្ត្រី **គួយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសាលាស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២៥។

-ចូលរួមក្នុងពិធីទទួលជំនួយពីមូលដ្ឋាននានា ក្នុងខេត្តកំពង់ឆ្នាំង សម្រាប់យកទៅឧបត្ថម្ភជូនដល់វីរកងទ័ពកម្ពុជានៅតាមសមរភូមិជួរមុខនិងឧបត្ថម្ភជូនដល់ប្រជាពលរដ្ឋ



ភៀសសឹកពីតំបន់គ្រោះថ្នាក់ដោយសង្គ្រាមឈ្លានពានពីភាគីថៃ ដែលមករស់នៅបណ្ដោះអាសន្នតាមកន្លែងមានសុវត្ថិភាព និងការដឹកជញ្ជូនពលករទៅកាន់លំនៅដ្ឋាន ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមគោរពវិញ្ញាណក្ខន្ធសព លោកព្រឹន្ទបាលឯក **ហេង តាំង** នាយរងការិយាល័យទី១ នៃបញ្ជាការដ្ឋានកងពលតូចអន្តរាគមន៍លេខ១ ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធដើម្បីបុព្វហេតុការពារទឹកដីពីសត្រូវឈ្លានពាន កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ៤៥ឆ្នាំ ក្រោមអធិបតីភាពឯកឧត្តម **ឆាយ ឫទ្ធិសែន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ស្ថិតនៅវត្តក្បាលកោះ ភូមិបឹងលាច ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន មន្ត្រីកសិកម្ម ប្រធានមណ្ឌលសុខភាព នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមេភូមិ ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពទូទៅរបស់ឃុំពិសេសគ្រួសារពលករមកពីប្រទេសថៃ និងគ្រួសារភៀសសឹកមកពីព្រំដែន ស្ថិតនៅសាលាឃុំព្រៃគ្រី ស្រុកជល់គិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥។

-ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត ចំនួន១០០គ្រួសារ និងគ្រួសារវីរកងទ័ពជួរមុខ ចំនួន៦៧គ្រួសារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាមន្ត្រី **គុយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសាលាឃុំពន្លៃ និងសាលាឃុំចក ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥។

-ចូលរួមពិធីសំណេះសំណាលជាមួយពលករដែលបានវិលត្រឡប់ពីប្រទេសថៃ ចំនួន៣៩គ្រួសារ និងគ្រួសារវីរកងទ័ព




ជួរមុខ ចំនួន១៩គ្រួសារ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី ស្ថិតនៅសាលប្រជុំរដ្ឋបាលក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៥។

❈នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង និងប្រជាពលរដ្ឋ នៅភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនឧបត្ថម្ភជូនដល់វីរកងទ័ព និងជនភៀសសឹកដែលរស់នៅឃុំគោកមន ស្រុកសំរោង ខេត្តឧត្តរមានជ័យ នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

-នាំយកថវិកាចូលបច្ច័យបុណ្យមួយចំនួនជូនក្រុមគ្រួសារកងទ័ព ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន ចំនួន៥រូប នៅខេត្តសៀមរាប នារសៀលថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ខី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ជឹម លាង** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យសព ឯកឧត្តម **នូ ធឿង** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអតីតអភិបាល នៃគណៈអភិបាលខេត្តក្រចេះ ដែលបានទទួលមរណភាពក្នុងជន្មាយុ៨០ឆ្នាំ ដោយជរាពាធ នៅគេហដ្ឋាននៃសព ស្ថិតនៅភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។




❈នាព្រឹកថ្ងៃពុធ ទី៣០ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា នាំយកសម្ភារៈ និងបរិក្ខារចាំបាច់មួយចំនួន ទៅជួយជនភៀសសឹកនៅតំបន់សុវត្ថិភាព នៅវត្តពោធិ៍៥០០០ដើម ព្រមទាំងប្រគល់សម្ភារៈជូនក្រុមការងារសង្គ្រោះនៅមណ្ឌលសុវត្ថិភាព រួមមាន៖ សេរ៉ូម និងបរិក្ខារពេទ្យមួយចំនួនដើម្បីប្រើប្រាស់ក្នុងការថែទាំសុខភាពប្រជាពលរដ្ឋ និងបាននាំយកអាវភ្លៀងចំនួន១៥០០ និងសំពត់តង់ធំចំនួន៥០ ដើម្បីចែកជូនប្រជាពលរដ្ឋតាមទីតាំងស្នាក់ការឃុំចំនួន៧ ដែលកំពុងទទួលជនភៀសសឹក ស្ថិតក្នុងខេត្តព្រះវិហារ។



❈នាថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធី «ទិវាជាតិអន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី៩ ឆ្នាំ២០២៥» ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងការប្រកាសស្តីពី

ការអនុវត្តគម្រោង «ពង្រឹងការចូលរួមរបស់ពលរដ្ឋក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។



❈នាថ្ងៃសៅរ៍ ទី៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញនាំយកថវិកាចំនួន៥០,០០០,០០០រៀល (ហាសិបលានរៀល) ប្រគល់ជូនឯកឧត្តម **ប្រាក់ សោភ័ណ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ដើម្បីយកទៅចាត់ចែងដល់វីរកងទ័ព និងប្រជាពលរដ្ឋភៀសសឹក នៅខេត្តសៀមរាប។



❈នាព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញប្រគល់អំណោយជូនប្រជាពលរដ្ឋភៀសសឹកមកពីខេត្តឧត្តរមានជ័យ សរុបចំនួន២០៥គ្រួសារ ដោយក្នុងមួយគ្រួសារទទួលបាន អង្ករចំនួន២៥គីឡូក្រាម, មីចំនួន១កេស គល់ស្លាបមាន់ចំនួន១គីឡូក្រាម, ត្រីខកំប៉ុងចំនួន១យួរ សាច់ក្រកចំនួន១គីឡូក្រាម, ប្រហុកលីងចំនួន១កែវ ផ្អកសាច់ជ្រូកចំនួន២កែវ, សាច់ជ្រូកប្រឡាក់ចំនួន១គីឡូក្រាម កាពិលីងចំនួន២កែវ, ខោអាវចំនួន១ឈុត និងថវិកាមួយចំនួន ព្រមទាំងប្រគេនព្រះសង្ឃនូវបច្ច័យ និងថវិកាមួយចំនួនជូន គណៈកម្មាធិការគ្រប់គ្រងជនភៀសសឹក នៅវត្តព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

❈នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញពិសាអាហារថ្ងៃត្រង់ការងារជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ និងលោកជំទាវឯកអគ្គរដ្ឋទូតសិង្ហបុរី នៅភោជនីយដ្ឋាន Ebinosekai Cambodia។

❈នាថ្ងៃសុក្រ ទី១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ទ៉ាន់ ចំរើន** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឆាយ ខណ្ណារ** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ខៃ៉ត ចដ្ឋាវី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានឧបត្ថម្ភថវិកាមួយចំនួនតាមការអំពាវនាវរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីរួមចំណែកលើកស្ទួយបុព្វហេតុការពារជាតិមាតុភូមិ ជាពិសេសដល់វីរយុទ្ធជន និងជនភៀសសឹកនៅតាមបណ្តាខេត្តនានាតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។



❈នាព្រឹកថ្ងៃសុក្រ ទី៨ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមការងារមួយចំនួន ដើម្បីទៅចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៦ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅអគាររដ្ឋបាល

ជាន់ទី១ បន្ទប់ហ្វូណាន វិមានរដ្ឋសភា។

❈នាថ្ងៃចន្ទ ទី២៨ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ហេង ហាលីម** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុន ចន្ថា** សមាជិកគណៈកម្មការ បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកសម្ភារៈ ព្រមទាំងស្បៀងបម្រុង រួមមាន៖ កាដុងទឹក តង់កៅស៊ូ មីយើង ឆៃប៉ូវ ត្រសក់ត្រាំ ផ្អកនិងប្រហុកដែលឆ្អិនស្រាប់ ពងទាឆ្អិន និងថវិកាមួយចំនួនជូនប្រជាពលរដ្ឋភៀសសឹក ចំនួន១៥០គ្រួសារ នៅវត្តភ្នំដី ស្ថិតក្នុងភូមិខ្នារ ឃុំក្រសាំង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។



❈នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញនាំយកសម្ភារៈរួមមាន ខ្ទឹមស ខ្ទឹ ទឹកឃ្មុំ ក្រូចឆ្មារ និងស្បៀងអាហារបម្រុង ប្រគល់ជូនអធិការដ្ឋាននគរបាលស្រុកចុងកាល់ ដើម្បីយកទៅឱ្យកងទ័ពជួរមុខ និងបន្តចុះសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក នៅជំរំវត្តបាត់ថ្មៅ ស្ថិតនៅភូមិបាត់ថ្មៅ ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។

❈នាថ្ងៃអាទិត្យ ទី១៧ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា អមដំណើរសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញធ្វើពិធីបួងសួងសុំ



សេចក្តីសុខសម្រាប់ប្រទេសកម្ពុជា នៅមុខប្រាសាទយាយព័ន្ធ នៃតំបន់ប្រាសាទសំបូរព្រៃគុក ស្ថិតក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ព្រមទាំងចូលថ្វាយបង្គំថ្វាយក្បួងផ្កាដល់ព្រះប្រតិមាមង្គល ដែលជាព្រះប្រតិមាអង្គថ្មីទើបរកឃើញ ដើម្បីសុំសេចក្តីសុខសន្តិភាពដល់ព្រះរាជាណាចក្រកម្ពុជា នៅសារមន្ទីរខេត្តកំពង់ធំ។



❈នារសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពវីរជនការពារព្រំដែននាយចំណង់ **មៀច សុខណាវាធីប** ពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសង្គ្រាមឈ្លានពានរបស់សៀមនៅសមរភូមិប្រាសាទតាក្របី ខេត្តព្រះវិហារ នៅលំនៅដ្ឋានគ្រួសារនៃសពស្ថិតនៅភូមិអូរគគី ឃុំអូរជា ស្រុកកំរៀង ខេត្តបាត់ដំបង។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ម៉ុំ សណ្តាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា និងសម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង/អញ្ជើញ៖

-ចូលរួមសួរសុខទុក្ខ និងនាំយកនូវព្រះរាជបណ្តាំ ផ្ញើសួរ



សុខទុក្ខ ព្រមទាំងពរជ័យ និងព្រះរាជទ្រព្យ ជាថវិកា សារុង និងសម្ភារៈមួយចំនួន ជូនយុទ្ធជនកងទ័ព និងជនកៀសសឹកសរុបចំនួន២០នាក់ នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខ និងនាំយកនូវព្រះរាជបណ្ដាំផ្ញើសួរសុខទុក្ខ ព្រមទាំងពរជ័យ និងព្រះរាជទ្រព្យ ជាថវិកា សារុង និងសម្ភារៈមួយចំនួនជូនយុទ្ធជន កងទ័ពចំនួន២១នាក់ នៅមន្ទីរពេទ្យព្រះកេតុមាលា រាជធានីភ្នំពេញ នារសៀលថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងសម្ដេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង/អញ្ជើញ៖



-គោរពវិញ្ញាណក្ខន្ធវីរជនការពារព្រំដែន លោកនាយចំណង់ **ម៉ៅ ស៊ា** ជាយោធិនក្នុងកងពលតូចអន្តរាគមន៍លេខ៨ នៃវរសេនាតូចលេខ៣៨២ ដែលបានពលីជីវិតលើសមរភូមិភ្នំទ្រព្យ ក្នុងពេលបំពេញបេសកកម្មការពារអធិបតេយ្យ និងបូរណភាពទឹកដី នៅតាមបណ្ដោយព្រំដែន កាលពីថ្ងៃសុក្រ ទី២៥ ខែសីហា ឆ្នាំ២០២៥ នៅលំនៅដ្ឋានគ្រួសារនៃសព ស្ថិតនៅ ក្នុងភូមិព្រៃជ្វរ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ នារសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥។



-គោរពវិញ្ញាណក្ខន្ធ និងរំលែកមរណទុក្ខ ជាមួយក្រុមគ្រួសារសព លោកវរសេនីយ៍ត្រី **សូត្រ ពេជ្រ** មេបញ្ជាការរងវរសេនាតូចលេខ៣៨២ នៃអង្គភាពទីបញ្ជាការមុខកងទ័ពជើងគោក ប្រចាំទិសយោធភូមិភាគទី៤ ដែលបានពលីជីវិតនៅលើសមរភូមិភ្នំទ្រព្យ ខេត្តព្រះវិហារ ក្នុងពេលបំពេញបេសកកម្មការពារអធិបតេយ្យ និងបូរណភាពទឹកដី នៅតាមបណ្ដោយព្រំដែន កាលពីថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ២០២៥ នៅលំនៅដ្ឋានគ្រួសារនៃសព ស្ថិតនៅក្នុងភូមិជំរងំ ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត នារសៀលថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥។

❋នាថ្ងៃសុក្រ ទី២២ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា



បានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី «កិច្ចសន្ទនាសភា៖ ការផ្សារភ្ជាប់ទំនាក់ទំនងសភារវាងសហភាពអឺរ៉ុប និងកម្ពុជា

(Parliamentary Dialogue : EU-Cambodia Parliamentary Network)» នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា។



❈នាព្រឹកថ្ងៃពុធ ទី៣០ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឆាយ ឫទ្ធា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈហាកិម និងក្រុមយុវជនចុះសួរសុខទុក្ខ ព្រមទាំងយកស្បៀងអាហារគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ជាច្រើនរបស់គណៈកម្មាធិការវិហារអ៊ីស្លាម ម៉ាស្ជិទអាល់អាក់ឡាភូមិព្រែកតាពៅ ក្រុមកាងារយុវជន និងប្រជាពលរដ្ឋដែលស្ថិតនៅភូមិព្រែកតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជូនបងប្អូនប្រជាពលរដ្ឋភៀសសឹកតំបន់ព្រំដែនកម្ពុជា-ថៃ ប្រគល់ជូនសាលាខេត្តសម្រាប់ចាត់ចែងជូនប្រជាពលរដ្ឋភៀសសឹកចំនួន១៨៥គ្រួសារ និងចែកជូនប្រជាពលរដ្ឋចំនួន១១៥គ្រួសារ នៅក្រុងសំរោង និងនៅវត្តភ្នំដី ឃុំក្រសាំង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។



❈នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមជប់លៀងអាហារពេលល្ងាចរបស់ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា នៅស្ថានទូតម៉ាឡេស៊ី មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖




-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងចែកអំណោយមនុស្សធម៌ជូនដល់ប្រជាជនភៀសសឹកចំនួន៥.០០០គ្រួសារ នៅវត្តពោធិ៍៥០០០ដើម ខេត្តព្រះវិហារ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនសាខាកាកបាទក្រហមកម្ពុជា ខេត្តព្រះវិហារ សម្រាប់ជួយដល់ជនភៀសសឹកផងដែរ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។



-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា គោរពវិញ្ញាណក្ខន្ធវីរកងទ័ព **ប៊ូ ផូ** ជាយោធិន ក្នុងកងពលតូចអន្តរាគមន៍លេខ៨ នៃកងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក ដែលពលីក្នុងសមរភូមិដើម្បីបុព្វហេតុជាតិមាតុភូមិនាពេលថ្មីៗនេះ នៅគេហដ្ឋានក្នុងភូមិវាលតូច ឃុំអណ្តូងពោធិ៍ ស្រុកតាំងគោក ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥។

❈នាថ្ងៃចន្ទ ទី៧ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា និងសម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង/អញ្ជើញនាំយក

នូវព្រះរាជបណ្ណាំផ្ញើសួរសុខទុក្ខ ព្រមទាំងពរជ័យ និងព្រះរាជ-ទ្រព្យ ជាថវិកានិងសារុង ជូនវីរកងទ័ព និងជនរងរបួសសរុបចំនួន១៤នាក់ និងបន្តទៅមន្ទីរពេទ្យព្រះកេតុមាលា មាន១៧នាក់ និងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត មាន២០នាក់។



❈នាព្រឹកថ្ងៃអង្គារ ទី៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **នូ ឡឿន** ទីប្រឹក្សារាជរដ្ឋាភិបាលនិងជាអតីតអភិបាលនៃគណៈអភិ-បាលខេត្តក្រចេះ នៅគេហដ្ឋាននៃសព ស្ថិតនៅភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។

❈សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានៈ

-យាងបរិច្ចាគឈាមជូនសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ ដឹកនាំដោយលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** ដើម្បីរួមចំណែកជួយដល់យុទ្ធជនក្នុងគ្រាបន្ទាន់ណាមួយ ស្ថិតនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានី




ភ្នំពេញ នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥។

-ព្រះរាជទានព្រះរាជទ្រព្យមួយចំនួនតាមការអំពាវនាវរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីលើកស្ទួយបុព្វហេតុការពារជាតិមាតុភូមិ ជាពិសេសដល់វីរយុទ្ធជន និងជនរងរបួសនៅតាមបណ្តាខេត្តនានាតាមបណ្តោយព្រំដែនកម្ពុជា-ថៃ នាថ្ងៃ២៩ ខែកក្កដា ឆ្នាំ២០២៥។

-យាងចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព លោកអនុសេនីយ៍ឯក **ពោ ខៃ** យោធានៃកងពលតូចអន្តរាគមន៍លេខ៨ និងលោកអនុសេនីយ៍ឯក **លៀម សំពៅមាស** មន្ត្រីនគរបាល នៃវរសេនាតូចនគរបាលការពារព្រំដែន៧៩៣ ដែលបានពលីជីវិតក្នុងបុព្វហេតុប្រយុទ្ធលើសមរភូមិជាមួយសៀមឈ្លានពាន និងបាននាំយកថវិការបស់ក្រុមសមាជិកាព្រឹទ្ធសភាមួយចំនួន រួមជាមួយព្រះរាជទ្រព្យផ្ទាល់ជូនក្នុងមួយគ្រួសារថវិកាមួយចំនួន នៅរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ចាប់ពីថ្ងៃទី២៤ ខែកក្កដា រហូតដល់ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥ លោកជំទាវ **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញអមដំណើរសម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណា-ចក្រកម្ពុជា អញ្ជើញចូលរួម «សន្និសីទប្រធានសភាពិភពលោក លើកទី៦ និងកិច្ចប្រជុំកំពូលលើកទី១៥ នៃប្រធានសភាជាស្ត្រី» នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស៕



# ឯកឧត្តម ឡាយ សំកុល អរគុណថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក និងយុវជន ស.ស.យ.ក នៃអ.ពស ចំពោះការចូលរួមវិភាគទានថវិកា ស្បៀងអាហារ ដល់វីរកងទ័ព និងប្រជាពលរដ្ឋភៀសសឹក



*ឯកឧត្តម ឡោក ឆាយ* *ឯកឧត្តម ឡាយ សំកុល* *ឯកឧត្តម ខេង សិទ្ធិគុណ* *ឯកឧត្តម អោក ប៉ូរ៉*

ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក នៃខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាទាំងបី និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមយុវជន ស.ស.យ.ក នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានចូលរួមគាំទ្រទាំងថវិកា ស្បៀងអាហារ កម្លាំងកាយ ចិត្ត និងស្មារតី ដល់វីរកងទ័ពនៅសមរភូមិមុខ និងប្រជាពលរដ្ឋភៀសសឹក នៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

**ឯកឧត្តមអគ្គលេខាធិការ** បានមានប្រសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសដែលឯកឧត្តមដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកក្កដានិងកំណត់ទិសដៅការងារខែសីហា ឆ្នាំ២០២៥ នាព្រឹកថ្ងៃពុធ ទី១៣ ខែសីហា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីតំណាងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង។

សូមជម្រាបថា មុននឹងចាប់ផ្តើមដំណើរការអង្គប្រជុំ **ឯកឧត្តមអគ្គលេខាធិការ** បានស្នើដល់អ្នកចូលរួមក្នុងអង្គប្រជុំទាំងអស់ ក្រោកឈរស្មិងស្មាធិ៍ដើម្បីគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់កងទ័ពថៃ។

នៅក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជាពិសេសភាពអង់អាចក្លាហានរបស់វីរកងទ័ពយើង និងការរួមចំណែកដ៏ធំធេងរបស់សម្តេចតេជោ **ហ៊ុន សែន** ជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការការពារបូរណភាពទឹកដី និងដែនអធិបតេយ្យជាតិ ពីការឈ្លានពានរបស់កងទ័ពថៃ។

បន្ថែមពីលើទិសដៅការងារ ដែលបានចាក់បញ្ចាំងក្នុងវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែកក្កដានិងទិសដៅការងារខែសីហា ឆ្នាំ២០២៥ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់គ្រប់អង្គភាពពាក់ព័ន្ធ ត្រៀមផ្តល់សេវាលើមុខងារនីតិកម្ម ដែលព្រឹទ្ធសភានឹងពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងនិងសេចក្តីស្នើច្បាប់ចំនួន២ នាពេលខាងមុខ។ ទន្ទឹមនឹងនោះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រៀមរៀបចំជំនួបសវនាការរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជាមួយប្រធានាធិបតីហ្វីលីពីន ប្រធានព្រឹទ្ធសភាម៉ាដាហ្គាស្កា ព្រមទាំងការអញ្ជើញទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

ចំពោះការងារអភិវឌ្ឍស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការ** បានបញ្ជាក់ប្រាប់ថា បន្ទាប់ពីបានទំនាក់ទំនងជាមួយសាកលវិទ្យាល័យនានា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានទទួលអាហារូបករណ៍ថ្នាក់បណ្ឌិតនិងអនុបណ្ឌិតជាង៤០កន្លែង។ ដូចនេះ អគ្គនាយកដ្ឋាននីមួយៗត្រូវពិនិត្យអំពីតម្រូវការ និងជំនាញពាក់ព័ន្ធនឹងអគ្គនាយកដ្ឋាន ដើម្បីផ្សព្វផ្សាយឱ្យមន្ត្រី

ដែលមានបំណងចង់សិក្សាបន្ត រៀបចំបែបបទ និងចុះឈ្មោះចូលរៀន។ ទាក់ទងនឹងការងារបច្ចេកវិទ្យាព័ត៌មាន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបង្កើតក្រុមការងារ ដែលមានអ្នកជំនាញជួយលើការងារជាយុទ្ធសាស្ត្រ ចក្ខុវិស័យ វិភាគប្រព័ន្ធទិន្នន័យ តម្រូវការ និងតាមដានការអនុវត្តលើដំណើរការរបស់យើង ដើម្បីឱ្យសម្រេចតាមផែនការមេស្តីពី បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក (២០២២-២០៣០)។ ជាមួយគ្នានោះ **ឯកឧត្តមអគ្គលេខាធិការ**បានស្នើដល់អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ធ្វើបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា (website) ជាប្រចាំ និងបញ្ចូលគេហទំព័ររបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា និងអង្គភាពផ្សេងទៀត ឱ្យស្ថិតក្រោមគេហទំព័រព្រឹទ្ធសភាតែមួយ ព្រមទាំងតាក់តែង និងសម្រួលអត្ថបទក្នុងទស្សនាវដ្ដីព្រឹទ្ធសភាឱ្យខ្លី ខ្លឹម និងមិនជាន់ពាក្យគ្នាដដែលៗ។



*ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប*

មុននឹងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ** បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ដែលបានខិតខំបំពេញការងារបានល្អប្រសើរនិងសូមបន្តខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយជូនស្ថាប័ន និងប្រទេសជាតិ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន







*ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងកំណត់ទិសដៅការងារខែសីហា ឆ្នាំ២០២៥*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមនាំយកទៀនព្រះវស្សា និងទេយ្យទានមួយចំនួនប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តស្បូវរីក ស្ថិតក្នុងភូមិស្បូវរីក ឃុំលាច និងវត្តកែវឧត្តម (ហៅវត្តកណ្ដាល) ស្ថិតក្នុងភូមិគល់ទទឹង ឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។



❈នារសៀលថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបប្រជុំជាមួយថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីត្រៀមរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋហ្វីលីពីន នៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមក្នុងពិធីសច្ចាប្រណិធានចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ សម្រាប់អាណត្តិទី៤ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង ព្រមទាំងចូលរួមកិច្ចប្រជុំលើកទី១ នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិទី៤ នៅទីស្ដីការអង្គភាពប្រឆាំងអំពើពុករលួយ។



❈នាល្ងាចថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **គឹម សំ** ម្ដាយបង្កើតរបស់ឯកឧត្តម **សោម សាវុធ** សមាជិកខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា និងលោក **សោម វុឌ្ឍារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាល្ងាចថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា ឯកឧត្តម **ខេង សិទ្ធិគុណា** និងឯកឧត្តម **អោក ម៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខម្តាយរបស់ឯកឧត្តម **រ័ត្ន ហុក** នាយករងខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



❈នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសំខាន់ៗប្រចាំត្រីមាសទី២ ព្រមទាំងលើកទិសដៅការងារបន្តរបស់ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោមវិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា បានអញ្ជើញដឹកនាំថ្នាក់ដឹកនាំ សមាជិកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **គឹម សំ** ម្តាយបង្កើតរបស់ឯកឧត្តម **សោម សាវុធ** សមាជិកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និងលោក **សោម វុទ្ធារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **សន ពៅ** នាយករងខុទ្ទកាល័យ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភា និងសហការី បានអញ្ជើញគោរពវិញ្ញាណក្ខន្ធឯកឧត្តមឧត្តមសេនីយ៍ឯក **ដួង សំឿន** ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយកងទ័ពថៃ នៅវត្តនិរោធរង្សី សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



❈នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **សន ពៅ** នាយករងខុទ្ទកាល័យ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ឆន់ ទឡ្ហនា** អនុប្រធានទី២ ព្រឹទ្ធសភា និងសហការី បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **គឹម សំ** ម្ដាយបង្កើតរបស់ឯកឧត្តម **សោម សាឍុធ** សមាជិកខុទ្ទកាល័យសម្ដេចតេជោប្រធានព្រឹទ្ធសភា និងលោក **សោម ឍុឆ្ឆារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលបានទទួលមរណភាពកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោង២២:០៣នាទីយប់ ក្នុងជន្មាយុ៨០ឆ្នាំ ដោយជរាពាធ។



❈នាព្រឹកថ្ងៃចន្ទ ទី២១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ជាម សុផលមករា** អគ្គនាយកព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **គឹម សំ** ម្ដាយបង្កើតរបស់ឯកឧត្តម **សោម សាឍុធ** សមាជិកខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា និងលោក **សោម ឍុឆ្ឆារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាព្រឹកថ្ងៃចន្ទ ទី២១ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម **ទេព ចរិយា** ប្រធានស.ស.យ.ក អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **គឹម សំ** ម្តាយបង្កើតរបស់ឯកឧត្តម **សោម សាវុធ** សមាជិកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និង លោក **សោម វុឌ្ឍារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ក្រុមការងារសហភាពសហព័ន្ធយុវជនកម្ពុជា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននាំយកកញ្ចប់ឃីតរួមមាន មី២០កញ្ចប់ ពងមាន់១ប្រអប់ ឆៃប៉ូវ១គីឡូក្រាម សៀង២ដប សាប៊ូ១ដុំ ធូបមូស១ដុំ ថ្នាំសង្កូវ១កញ្ចប់ ជូនដល់គ្រួសារភៀសសឹក ចំនួន៣០០គ្រួសារ នៅវត្តទួលអណ្តែត ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ។



❈នារសៀលថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ក្រុមការងារសហភាពសហព័ន្ធយុវជនកម្ពុជានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបន្តនាំយកកញ្ចប់ឃីតរួមមាន តង់១ សាប៊ូ២ដុំ ធូបមូស៣ដុំ ជូនដល់គ្រួសារភៀសសឹក ពីការឈ្លានពានរបស់ទាហានថៃ ចំនួន៧៩គ្រួសារ នៅវត្តព្រះលាន (ហៅវត្តក្រាំងដូង) ស្ថិតនៅភូមិក្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្បែង-មានជ័យ ខេត្តព្រះវិហារ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ: (855) 23 211 441, 211 442, 211 443 ទូរសារ: (855) 23 211 446

E-mail: secretariat@senate.gov.kh

www.senate.gov.kh www.elibrary.senate.gov.kh

senate of cambodia